**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiqes

Royal Unitersity of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិលើការបញ្ចាំអចលនវត្ថុ

ស្រាវជ្រាវ ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយនិស្សិត ៖

លោក **ហេង សុនា**

កញ្ញា **ហាក់ ស្រីពៅ**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហេង សុនា** និងនាងខ្ញុំឈ្មោះ **ហាក់ ស្រីពៅ** ជានិស្សិតថ្នាក់ L4C2 ជំនាញ **នីតិសាស្ត្រ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងអណេកចំពោះលោកអ្នកមានគុណ ៖

លោកឪពុក **ហេង លួន** និងអ្នកម្តាយ **គៀត ចាន់** ព្រមទាំង

លោកឪពុក **ម៉ិល ឌីម៉ង់** និងអ្នកម្តាយ **ទូច សុខា**

ដែលបានផ្តល់នូវកំណើត និងកាយសម្បទាមាំមួនដែលមិនអាចកាត់ថ្លៃបានចំពោះយើងខ្ញុំ ព្រមទាំងចំណាយអស់នូវកម្លាំងថាមពលរបស់លោកអ្នកមានគុណ ដើម្បីចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់នូវការឧបត្ថម្ភចំពោះយើងខ្ញុំ រហូតទទួលបាននូវ ការសិក្សាអប់រំ ទូន្មានប្រៀនប្រដៅ ដើម្បីឱ្យទទួលបាននូវចំណេះដឹង រួមទាំងបទពិសោធន៍ជីវិត ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍន៍ចំណេះដឹង ដើម្បីយកទៅបម្រើសង្គមជាតិឱ្យមានភាពរីកចម្រើន។ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់ដែលមាននៅក្នុងលោកនេះ ឱ្យតាមថែរក្សាលោកអ្នកមានគុណឱ្យទទួលបាននូវសុខភាពល្អ កម្លាំងកាយមាំមួន អាយុយឺនយូរដើម្បីគង់ជាម្លប់ដល់យើងខ្ញុំដែលជាកូន ជាចៅជាសាច់សាលោហិតនៃលោកអ្នកមានគុណ ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបានផ្តល់នូវទីតាំង ជាពិសេសទឹកចិត្តសណ្តោះប្រណីចំពោះសិស្ស និស្សិតទាំងអស់ ទាំងអ្នកមានធនធានក្តី និងអ្នកមិនមានធនធានក្តី ឱ្យមានឱកាសក្នុងការសិក្សារៀនសូត្រ ទទួលបានចំណេះដឹង ក៏ដូចជាបទពិសោន៍ល្អៗ ពីសាស្ត្រាចារ្យដែលមានជំនាញ និងបទពិសោធន៍ ដើម្បីជាស្ពានចម្លងយើងខ្ញុំឱ្យទទួលបានអនាគតល្អប្រសើរ ។

ជាពិសេសក៏សូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យ ទេព សុខ** ដែលជាសាស្ត្រាចារ្យជំនាញ ដែលមានបទពិសោធន៍ក្នុងការបង្រៀនជាច្រើនឆ្នាំ និងបង្រៀនដល់យើងខ្ញុំ និងសិស្សច្បងជំនាន់មុនក៏ទទួលបានការបណ្តុះបណ្តាលពីលោក ឱ្យក្លាយជាធនធានមនុស្សក្នុងសង្គម និងទទួលបានបទពិសោធន៍ក្នុងការអភិវឌ្ឍន៍ចំណេះដឹងជាច្រើន។ ហើយលោកក៏ជាសាស្ត្រាចារ្យឆ្នើមមួយរូប ដែលបានដឹកនាំយើងខ្ញុំទាំងពីរក្នុងការសិក្សាស្រាវជ្រាវចងក្រងនូវសៀវភៅមួយក្បាលនេះគឺ «សិទ្ធិលើការបញ្ចាំអចលនវត្ថុ» ឱ្យទទួលបានជោគជ័យមួយរយភាគរយ ដើម្បីជាស្នាដៃមួយទុកតម្កល់សម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយឱ្យទទួលបាននូវចំណេះដឹងបន្ថែមទៀតពីសៀវភៅមួយក្បាលនេះ។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម ឈី សម្បត្តិ** ប្រធានក្រុមហ៊ុនមេធាវី សម្ព័ន្ធអ្នកការពារក្តីកម្ពុ-ជា ដែលបានផ្តល់នូវដំបូន្មានល្អៗ និងបានអនុញ្ញាតឱ្យយើងខ្ញុំបានទៅសិក្សាស្រាវជ្រាវនៅក្នុងក្រុមហ៊ុនរបស់លោក ដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតចំពោះកិច្ចការនេះ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបណ្តុះបណ្តាលយើងខ្ញុំ ក៏ដូចជានិស្សិតទាំងអស់តាំងពីដើមដំបូងមក ឱ្យមានអនាគតល្អប្រសើរ និងក្លាយជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមជួយអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន។ យើងខ្ញុំសូមគោរពជូនពរលោកសាស្ត្រាចារ្យទាំងអស់ ឱ្យទទួលបាននូវសេចក្តីសុខពេញមួយជីវិត មានសុខភាពល្អប្រសើរ មានកម្លាំងកាយមាំមួន មានសុភមង្គលក្នុងគ្រួសារ និងជួបប្រទះនូវភាពជោគជ័យជារៀងរហូតតទៅ។

ពីយើងខ្ញុំជានិស្សិតរបស់លោក ៖ ខ្ញុំបាទ ហេង សុភា និងនាងខ្ញុំ ហាក់ ស្រីពៅ

# អារម្ភកថា

នៅក្នុងរយៈពេលនៃការសិក្សាជំនាញនីតិសាស្រ្តក្នុងរយៈពេល ៤ឆ្នាំនេះមក យើងខ្ញុំបានសិក្សាស្វែងយល់បានច្បាស់ថាវិស័យច្បាប់ (នីតិសាស្រ្ត) នេះ គឺដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមរស់នៅ និងនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ជាពិសេសវិស័យតុលាការ។ ដោយហេតុថា នៅក្នុងប្រទេសនីមួយៗមិនអាចគ្មានច្បាប់ដើម្បីអនុវត្តបាននោះទេ ព្រោះតាមន័យនីតិសាស្រ្ត ច្បាប់គឺជាវិធានទាំងឡាយ ដែលគ្រប់គ្រងការរស់នៅក្នុងសង្គម ធ្វើយ៉ាងណាឱ្យសង្គមមនុស្សទាំងមូលមានរបៀបរបប មានសុវត្ថិភាព សេចក្ដីថ្លៃថ្នូរ និងរីកចម្រើន។ ប្រធានបទដែលយើងខ្ញុំបានស្រាវជ្រាវ និងលើកយកមកបង្ហាញគឺ "**សិទ្ធិលើការបញ្ចាំអចលនវត្ថុ**"។

យើងខ្ញុំសង្ឃឹមថាសារណាក្រោមប្រធានបទខាងលើនេះ នឹងក្លាយជាវិភាគទានមួយចំណែកក្នុងវិស័យនីតិសាស្រ្ត និងចំពោះអ្នកសិក្សាជំនាន់ៗក្រោយ អ្នកស្រាវជ្រាវ ដើម្បីជាប្រយោជន៍ក្នុងការពង្រីកចំណេះដឹងរបស់ខ្លួន។ ហេតុនេះហើយ ទើបយើងខ្ញុំលើកយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ និងយល់ឃើញថាវានឹងជួយអ្នកសិក្សាជំនាន់ក្រោយ និងអ្នកស្រាវជ្រាវទាំងអស់ដើម្បីងាយស្រួលក្នុងការសិក្សាឈ្វេងយល់បន្ថែម និងជាក្បួនច្បាប់ក្នុងការរស់នៅក្នុងសង្គម។ គោលបំណងសំខាន់បន្ទាប់ពីនេះគឺ ការតម្កល់ស្នាដៃនេះក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្លាយជាអនុស្សាវរីយ៍មួយក្នុងសាកលវិទ្យាល័យដែលយើងខ្ញុំបានសិក្សា និងជាកន្លែងផ្ដល់ចំណេះដឹង ចំណេះធ្វើ គំនិត ស្មារតី បញ្ញា និងសមត្ថភាពដែលអាចឱ្យយើងខ្ញុំចងក្រងសារណានេះឡើងប្រកបដោយជោគជ័យ និងជាទីមោទនភាព។

នៅក្នុងការស្រាវជ្រាវចងក្រងសារណានេះ ទោះបីយើងខ្ញុំខិតខំព្យាយាមពិនិត្យយ៉ាងណាក៏អាចនៅមានចំណុចខ្វះខាតដោយអចេតនាជាក់ជាពុំខាន។ ដូច្នេះហើយ យើងខ្ញុំសូមអភ័យទោសពីលោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ និងបងប្អូននិស្សិតជាមុន រាល់កំហុសខុសឆ្គងដោយអចេតនា។

យើងខ្ញុំទាំងពីរនាក់ សូមស្វាគមន៍នូវរាល់ការរិះគន់បែបស្ថាបនារបស់ លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ និងបងប្អូននិស្សិតទាំងអស់ ដើម្បីកែលម្អនូវចំណុចខ្វះខាតទាំងអស់ដែលមានក្នុងការស្រាវជ្រាវមួយនេះ និងទុកគំនិតរិះគន់នេះជាប្រទីបបំភ្លឺផ្លូវឈានទៅរកភាពជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមជូនពរដល់ លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ និងបងប្អូននិស្សិតទាំងអស់ ក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូបឱ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និងទទួលនូវជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**១.១ ទិដ្ឋភាពទូទៅនៃសិទ្ធិលើការបញ្ចាំ** ........................................ ៥

១.១.១ ទំហំនៃការធានាសិទ្ធិលើបំណុល ........................................ ៥

១.១.២ ការបញ្ចាំបន្ត ........................................ ៦

១.១.៣ ការហាមការបញ្ចាំផ្តាច់ ........................................ ៦

១.១.៤ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ........................................ ៧

**១.២ សិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ** ........................................ ៨

១.២.១ សិទ្ធិកាន់កាប់ ........................................ ៨

១.២.២ សិទ្ធិឃាត់ទុក ........................................ ៩

១.២.៣ សិទ្ធិទទួលផលពីកម្មវត្ថុនៃការបញ្ចាំដោយមានអាទិភាព ........................................ ៩

**១.៣ កម្មវត្ថុនៃការបញ្ចាំ** ........................................ ១០

១.៣.១ ការដាក់បញ្ចាំអចលនវត្ថុ ........................................ ១០

១.៣.២ ការដាក់បញ្ចាំចលនវត្ថុ ........................................ ១៣

១.៣.៣ ការបញ្ចាំសិទ្ធិ ........................................ ១៣

**២.១ ការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ** ........................................ ១៤

២.១.១ លក្ខខណ្ឌទម្រង់ ........................................ ១៤

២.១.២ លក្ខខណ្ឌគ្រឹះ ........................................ ១៥

២.១.២.១ ឆន្ទៈក្នុងការបង្កើតកិច្ចសន្យា ........................................ ១៥

២.១.២.២ ការបង្កើតកិច្ចសន្យាដោយមានវិការៈ ........................................ ១៥

២.១.៣ មោឃភាព និងការលុបចោល........................................................................................ ១៨

២.១.៣.១ មោឃភាព ........................................................................................................... ១៨

២.១.៣.២ ការលុបចោល ....................................................................................................... ១៨

**២.២ រយៈពេលបញ្ចាំ និងអានុភាព**.........................................................................................១៩

២.២.១ រយៈពេលបញ្ចាំអចលនវត្ថុ ...............................................................................................១៩

២.២.២ អានុភាពនៃការបញ្ចាំអចលនវត្ថុ........................................................................................ ២០

**២.៣ ៖ ការអនុវត្តកិច្ចសន្យាបញ្ចាំអចលនវត្ថុ**.................................................................................. ២១

២.៣.១ សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ............................................................ ២១

២.៣.១.១ ផលុបភោគ ...................................................................................................... ២២

២.៣.១.២ ការបញ្ចាំបន្ត.................................................................................................... ២២

២.៣.១.៣ ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល ..........................................................................២៣

ក. ការអនុវត្តដោយបង្ខំ និងលក្ខខណ្ឌ.........................................................................................២៣

ខ. លិខិតអនុវត្ត ....................................................................................................................២៤

គ. ការអនុវត្ត........................................................................................................................២៥

ឃ. លក្ខខណ្ឌនៃការលក់ ..........................................................................................................២៥

ង. វិធីលក់ ...........................................................................................................................២៥

ច. អានុភាពនៃការលក់............................................................................................................ ២៦

២.៣.២ កាតព្វកិច្ចរបស់ម្ចាស់បំណុល............................................................................................ ២៦

២.៣.២.១ កាតកិច្ចប្រគល់វត្ថុបញ្ចាំ ....................................................................................... ២៦

២.៣.២.២ ថែរក្សា ឬចេញសោហ៊ុយ ..................................................................................... ២៧

២.៣.៣ សិទ្ធិ និងកាតព្វកិច្ចនៃអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ......................................................... ២៧

**៣.១ មូលហេតុនៃការរំលត់កាតព្វកិច្ច**............................................................................................២៩

៣.១.១ ការសង ........................................................................................................ ២៩
៣.១.២ ការទូទាត់ ........................................................................................................ ៣០
៣.១.៣ ការលើកលែង និងការរំលត់កាតព្វកិច្ចដោយអលទ្ធភាព ........................................ ៣១
៣.១.៤ ការមិនអនុវត្តកាតព្វកិច្ច ........................................................................................ ៣១
៣.១.៥ ផុតអាជ្ញាយុកាល .................................................................................................. ៣២
៣.១.៦ នវកម្ម .................................................................................................................. ៣៣
៣.១.៧ ព្យាកុលភាព ......................................................................................................... ៣៣
**៣.២ លក្ខណៈដូចគ្នា និងខុសគ្នារវាងហ៊ីប៉ូតែក ជាមួយការបញ្ចាំអចលនវត្ថុ** ............. ៣៣
៣.២.១ លក្ខណៈដូចគ្នា ....................................................................................................... ៣៤
៣.២.១ លក្ខខណៈខុសគ្នា ..................................................................................................... ៣៥
**សេចក្តីសន្និដ្ឋាន** ................................................................................................................ ៣៤
**អនុសាសន៍** ........................................................................................................................ ៣៧

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ការបញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាមួយក្នុងចំណោមកិច្ចសន្យាជាច្រើនទៀតដែលមានចែងក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ភូមិបាល ដែលនិយាយអំពីការបញ្ចាំអចលនវត្ថុនៅប្រទេសកម្ពុជា។ ការបញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាដែលកូនបំណុលប្រគល់អចលនវត្ថុ ដែលជាកម្មវត្ថុនៃការបញ្ចាំឱ្យទៅម្ចាស់បំណុលរបស់ខ្លួនធ្វើការកាន់កាប់ដើម្បីធានាការសងបំណុល។ អចលនវត្ថុ សំដៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។ បុគ្គលដែលយកអចលនវត្ថុទៅដាក់បញ្ចាំឈ្មោះថា កូនបំណុល ឯអ្នកទទួលបញ្ចាំឈ្មោះថា ម្ចាស់សិទ្ធិលើការបញ្ចាំ។

ដោយសារការបញ្ចាំលើអចលនវត្ថុ ជាបច្ចុប្បន្នភាពនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ គ្រប់និន្នាការនយោបាយ ទាំងអ្នកតូច អ្នកធំ ទាំងអ្នកមាន និងអ្នកក្រ សុទ្ធតែត្រូវបានឆ្លងកាត់ការបញ្ចាំអចលនវត្ថុ ដើម្បីយកដើមទុនមកពង្រីកសេដ្ឋកិច្ចជីវភាព និងការអភិវឌ្ឍគ្រួសាររបស់ខ្លួន។ ហេតុដូចនេះហើយ ទើបក្រុមយើងខ្ញុំលើកយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ។

ការបញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាដែលតាមកិច្ចសន្យានោះ កូនបំណុលប្រគល់ឱ្យម្ចាស់បំណុលរបស់ខ្លួននូវទ្រព្យមួយដើម្បីធានាការសងបំណុល មានន័យថាដើម្បីធានាបំណុលរបស់ខ្លួន តម្រូវឱ្យកូនបំណុលប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់បំណុលជាចាំបាច់។ រីឯ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬតតិយជន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត មានន័យថាការបញ្ចាំ គឺអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ (ម្ចាស់បំណុល) កាន់កាប់នូវវត្ថុបញ្ចាំដែលបានទទួលពីកូនបំណុល និងទទួលសំណងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដែលបានមកពីតម្លៃថ្លៃថ្នូរនៃវត្ថុនោះ មានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។

យ៉ាងណាមិញ ការស្រាវជ្រាវសារណាស្តីពី សិទ្ធិលើការបញ្ចាំអចលនវត្ថុ ដែលយើងខ្ញុំជានិស្សិតច្បាប់បានខិតខំស្រាវជ្រាវយកមកសរសេរយ៉ាងក្បោះក្បាយ ពាក់ព័ន្ធការដាក់បញ្ចាំអចលនវត្ថុ ជាពិសេស នីតិវិធីការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ ឱ្យស្របតាមច្បាប់ដើម្បីការពារផលប្រយោជន៍ដល់កូនបំណុល និងម្ចាស់សិទ្ធិលើការបញ្ចាំ មកធ្វើការបង្ហាញដល់សាធារណជន ដើម្បីឱ្យកាន់តែលម្អិតអំពីវិស័យច្បាប់ដែលពាក់ព័ន្ធទៅនឹងសិទ្ធិលើការបញ្ចាំអចលនវត្ថុ ការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ និងការអនុវត្តរបស់គូភាគីក្នុងកិច្ចសន្យា។ យើងខ្ញុំសង្ឃឹមថា ឯកសារនេះនឹងបានចូលរួមជាចំណែកដល់ សិស្ស និស្សិត និងប្រជាពលរដ្ឋក្នុងការស្រាវជ្រាវស្វែងយល់ផងដែរ។

ជាទូទៅ ការដាក់បញ្ចាំអចលនវត្ថុ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ចែងមក ដើម្បីរក្សានូវផលប្រយោជន៍ និងបញ្ចៀសការកើតឡើងនូវវិវាទ រវាងកូនបំណុល និងម្ចាស់សិទ្ធិលើការបញ្ចាំ ប៉ុន្តែនៅមានប្រជាជនមួយចំនួនពុំទាន់យល់ច្បាស់ពីតួនាទីការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ជាពិសេសការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុឱ្យបានច្បាស់លាស់ឡើយ។ ស្របពេលនេះវាពិតជាមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋក្នុងការសិក្សាស្វែងយល់។ ការសិក្សាស្វែងយល់ពីសិទ្ធិលើការបញ្ចាំអចលនវត្ថុ គឺជាការចាំបាច់សម្រាប់អ្នកសិក្សាស្រាវជ្រាវទាំងឡាយ និងប្រជាជននៅក្នុងសង្គមជាតិ ព្រោះនេះជាតម្រូវការចាំបាច់សម្រាប់ប្រជាពលរដ្ឋក្នុងការការពារផលប្រយោជន៍ក្នុងការដាក់បញ្ចាំអចលនវត្ថុដែលពួកគេត្រូវការសម្រាប់ខ្លួនឯង។ ដូចនេះ ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវធ្វើឡើងដោយមានចំណោទបញ្ហាដូចតទៅ៖

- តើសញ្ញាណគតិយុត្តនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុប្រព្រឹត្តទៅដូចម្តេច?
- តើនីតិវិធីក្នុងការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- ក្រោយពីបង្កើតកិច្ចសន្យា តើកូនបំណុល និងម្ចាស់សិទ្ធិលើការបញ្ចាំមានតួនាទី និងសិទ្ធិដូចម្តេចខ្លះ? តើមានមូលហេតុអ្វីខ្លះទើបបណ្តាលឱ្យមានការរំលត់កាតព្វកិច្ចនៃការបញ្ចាំអចលនវត្ថុ?

ដើម្បីឱ្យជ្រាបកាន់តែច្បាស់ទៅលើប្រធានបទ និងឈានដល់ការបកស្រាយនូវខ្លឹមសារទាំងមូលឱ្យបានក្បោះក្បាយ និងស៊ីជម្រៅ ក្រុមយើងខ្ញុំនឹងធ្វើការឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធទាំងនោះ ដោយធ្វើការបកស្រាយនៅក្នុងប្រធានបទសារណានេះទាំងមូល ។

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវខាងលើនេះ យើងខ្ញុំបានស្រាវជ្រាវយកមកសរសេរចងក្រងឡើង ដោយមានគោលបំណងផ្តោតសំខាន់ដូចជា៖

- ដើម្បីយល់ដឹងពីសិទ្ធិលើការបញ្ចាំអចលនវត្ថុ និងនីតិវិធី ព្រមទាំងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុឱ្យបានច្បាស់លាស់។
- ដើម្បីផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់អំពីសិទ្ធិលើការបញ្ចាំអចលនវត្ថុឱ្យបានស៊ីជម្រៅ។
- ដើម្បីតម្កល់ទុកជាឯកសារជំនួយដល់អ្នកសិក្សាជំនាន់ក្រោយ ក្នុងការសិក្សាស្វែងយល់បន្ថែមទៀតពីសិទ្ធិលើការបញ្ចាំអចលនវត្ថុ។

របាយការណ៍សិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតសំខាន់លើសិទ្ធិលើការបញ្ចាំអចលនវត្ថុ លក្ខខណ្ឌ និងនីតិវិធីនៃការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ ពួកយើងនឹងធ្វើការបកស្រាយទាក់ទងនឹងសិទ្ធិលើការបញ្ចាំអចលនវត្ថុ លក្ខខណ្ឌ និងនីតិវិធីនៃការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ភូមិបាល។

**ទំហំនៃការស្រាវជ្រាវ និងដែនកំណត់នៃការស្រាវជ្រាវ៖** គឺប្រធានបទនេះ យើងខ្ញុំសិក្សាទៅលើបរិបទខ្លឹមសារដែលមាននៅក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ភូមិបាល និងការអនុវត្តជាក់ស្តែងក្នុងសង្គម។

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទណាមួយ គឺពិតណាស់តែងតែជួបការលំបាក ព្រោះយើងត្រូវការចំណាយពេលវេលាច្រើន ចំណាយកម្លាំងកាយចិត្ត ក៏ដូចជាថវិកាជាដើម ជាពិសេសគឺត្រូវមានចំណង់ចំណូលចិត្ត និងការព្យាយាមបន្ថែមទៀតផងដែរ ទើបការសិក្សាស្រាវជ្រាវរបស់យើងទទួលបានជោគជ័យ ។

ទោះបីមានការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែខិតខំជម្នះឱ្យទាល់តែបាន ពីព្រោះថាការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យើងខ្ញុំដែលក្នុងនោះរួមមានដូចជា៖

- ទទួលបានចំណេះដឹងថ្មីៗពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ
- យល់ដឹងកាន់តែលម្អិតទៅលើប្រធានបទ ដែលសិក្សាស្រាវជ្រាវ
- ទទួលបានប្រភពឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ
- ចេះធ្វើការប្រៀបធៀបរវាងចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយ
- ទទួលបានបទពិសោធន៍ល្អៗពីអ្នកមានចំណេះដឹង ព្រមទាំងអ្នកមានបទពិសោធន៍
- យល់កាន់តែច្បាស់បន្ថែមទៀត អំពីការរៀបប្រយោគ ឃ្លោងឃ្លា អក្ខរាវិរុទ្ធ
- ជាពិសសគឺបានបន្សល់ស្នាដៃទុកសម្រាប់សិស្ស និស្សិត បានសិក្សាស្រាវជ្រាវបន្តទៀត ។

ចំពោះវិធីសាស្ត្រប្រមូលទិន្នន័យ គឺយើងខ្ញុំបានសម្រេចចិត្តរៀបរៀងសរសេរសារណានេះឡើង ដោយបានធ្វើការប្រមូលទិន្នន័យ គឺតាមបែបគុណវិស័យ ដែលជាទិន្នន័យបានមកពីការប្រមូលឯកសារ ទ្រឹស្តី ព័ត៌មាន របាយការណ៍ ការជួបសម្ភាសន៍ ការសាកសួរដោយផ្ទាល់មាត់ ការស្នើសុំឯកសារ និងរបាយការណ៍ ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវនេះទទួលបានភាពជោគជ័យ ។

ចំពោះប្រភព និងប្រភេទនៃវិធីប្រមូលទិន្នន័យ ឯកសារ និងព័ត៌មាន ដែលបានសរសេរតាមគុណវិស័យរួមមាន៖

- ក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ២០០៧

-ច្បាប់ភូមិបាលឆ្នាំ២០០១

- ឯកសារច្បាប់ផ្សេងទៀតដែលចងក្រងដោយសាស្ត្រាចារ្យ

- ការជួបសម្ភាសន៍ជាមួយសាស្ត្រចារ្យណែនាំសារណាក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធផងដែរ និង

- ការប្រមូលឯកសារទិន្នន័យជាច្រើនទៀតតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

បន្ទាប់ពីប្រមូលឯកសារ និងរបាយការណ៍បានគ្រប់គ្រាន់ហើយ យើងខ្ញុំបានប្រើប្រាស់វិធីចងក្រងឯកសារទៅតាមផ្នែកនីមួយៗ ដើម្បីកុំឱ្យមានការភ័ន្តច្រឡំគ្នា ហើយក៏បានវាយឯកសារទាំងនោះបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ទៅតាមប្រភេទ និងផ្នែកដែលបានព្រៀងទុក។

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវប្រធានបទ "សិទ្ធិលើការបញ្ចាំអចលនវត្ថុ" គឺត្រូវបានបែងចែករចនាសម្ព័ន្ធចេញជា៣ជំពូកសំខាន់ៗដូចខាងក្រោម៖

- **ជំពូកទី១ សញ្ញាណទូទៅនៃសិទ្ធិលើការបញ្ចាំ** ៖ គឺជាការបង្ហាញឱ្យឃើញនូវសកម្មភាពទូទៅមួយដែលមាននៅក្នុងខ្លឹមសារ។
- **ជំពូកទី២ នីតិវិធីនៃការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ និងការអនុវត្តកិច្ចសន្យា** ៖ ក្នុងជំពូកនេះគឺសរសេររៀបរាប់ពីលក្ខខណ្ឌទម្រង់ លក្ខខណ្ឌគ្រឹះ រយៈពេល និងអានុភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ។
- **ជំពូកទី៣ ការរំលត់កាតព្វកិច្ចនៃការបញ្ចាំអចលនវត្ថុ** ៖ នៅក្នុងជំពូកនេះ គឺសរសេររៀបរាប់ពី មូលហេតុនៃការរំលត់សិទ្ធិ និងភាពខុសគ្នារវាងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ។

# ជំពូកទី១

# សញ្ញាណទូទៅនៃសិទ្ធិលើ

# ការបញ្ចាំ

# ជំពូកទី១
# សញ្ញាញទូទៅនៃសិទ្ធិលើការបញ្ចាំ

## ១.១ ទិដ្ឋភាពទូទៅនៃសិទ្ធិលើការបញ្ចាំ

ក្នុងទិដ្ឋភាពទូទៅនៃសិទ្ធិលើការបញ្ចាំ គឺជាការបង្ហាញឱ្យឃើញនូវសកម្មភាពទូទៅមួយដែលមាននៅក្នុងខ្លឹមសារ។ ខាងក្រោមនេះគឺជាការបង្ហាញន័យរួមចំពោះការបញ្ចាំទាំងអស់ ទាំងអចលនវត្ថុ ចលនវត្ថុ និងការបញ្ចាំសិទ្ធិ។ ខាងក្រោមនេះនឹងបង្ហាញពីទិដ្ឋភាពរួមនៃសិទ្ធិលើការបញ្ចាំ ដែលបង្ហាញអំពី (១) ទំហំនៃការធានាសិទ្ធិលើបំណុល, (២) ហាមឃាត់ការបញ្ចាំផ្តាច់ និង (៣) អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល ។

### ១.១.១ ទំហំនៃការធានាសិទ្ធិលើបំណុល

សិទ្ធិលើការបញ្ចាំត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ធានាសង ក្នុងករណីមិនគោរពកិច្ចសន្យាសោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ។[1]

ដើមបំណុល ឬហៅថាម្ចាស់បំណុល គ្មានសិទ្ធិចាត់ចែងវត្ថុបញ្ចាំតាមទំនើងចិត្តរបស់ខ្លួនបានទេ។ ដើមបំណុលមានករណីកិច្ចទុកវត្ថុនោះឱ្យបានគង់វង្ស និងថែរក្សាឱ្យបានល្អ។ ក្នុងករណីដែលវត្ថុបញ្ចាំនោះត្រូវខូចខាត ឬបាត់បង់បណ្តាលមកពីកំហុសរបស់ខ្លួន ដើមបំណុលត្រូវជួសជុលសំណងវត្ថុបញ្ចាំនោះ។

ប្រសិនបើគ្មានកំណត់ក្នុងកិច្ចសន្យាជាលាយលក្ខណ៍អក្សរច្បាស់លាស់ទេ ដើមបំណុលមិនត្រូវបានអនុញ្ញាតិឱ្យយកវត្ថុបញ្ចាំនោះទៅប្រើប្រាស់ទេ ឬទាយយកផលប្រយោជន៍ពីវត្ថុបញ្ចាំនោះបានទេ។ ប៉ុន្តែដើមបំណុលត្រូវបានអនុញ្ញាតឱ្យទទួលយកផលធម្មជាតិ នៃវត្ថុបញ្ចាំនោះបាន។ ផលនោះទុកជាអទិភាពសម្រាប់ចំណាយចាំបាច់ទាំងឡាយ។ ប្រសិនបើដើមបំណុលប្រើវត្ថុបញ្ចាំនោះដោយរំលោភលើកិច្ចសន្យា កូនបំណុលអាចសុំប្តឹងដកវត្ថុបញ្ចាំមកវិញបាន ។[2]

*ឧទាហរណ៍ ៖* បុគ្គល ក បានយកទ្រព្យសម្បត្តិមកដាក់បញ្ចាំ ជាមួយបុគ្គល ខ ដើម្បីទទួលបានប្រាក់ ដូច្នេះបុគ្គល ខ ត្រូវតែថែរក្សាទ្រព្យសម្បត្តិនោះឱ្យបានល្អក្នុងនាមជាអ្នកគ្រប់គ្រងដោយសុច្ចរិត ប្រសិនបើពុំមានការយល់ព្រមពីកូនបំណុលទេនោះ ដើមបំណុល ឬម្ចាស់បំណុល មិនអាចយកទ្រព្យសម្បត្តិនោះទៅប្រើប្រាស់ ឬទាញយកផលប្រយោជន៍បានឡើយ លើកលែងតែការទទួលបានផលពីធម្មជាតិ ។

[1] មាត្រា៨២០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[2] មាត្រា ៦៦ និង៦៧ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា នៃសាធារណរដ្ឋមានិតកម្ពុជា

### ១.១.២ ការបញ្ចាំបន្ត

ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើកាបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវចំពោះការខូចខាតដោយប្រធានសក្តិដែលមិនអាចកើតមានឡើង ប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ។

នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តអាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ប៉ុន្តែ ប្រសិនបើសិទ្ធិលើបំណុលរបស់ខ្លួនមិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តគ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ។[3]

### ១.១.៣ ការហាមការបញ្ចាំផ្តាច់

ថ្វីត្បិតតែកិច្ចសន្យាបញ្ចាំ ត្រូវបានធ្វើឡើងផ្អែកលើការព្រមព្រៀងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតកិច្ចសន្យាបញ្ចាំតាម "គោលការស្វ័យភាពនៃបុគ្គលឯកជន" ប៉ុន្តែច្បាប់បានកំរិតនូវសិទ្ធិមួយចំនួន ចំពោះភាគីនៃការបញ្ចាំ មិនឱ្យបង្កើតនូវកិច្ចសន្យាបញ្ចាំផ្តាច់ដែលបានធ្វើមុនកំណត់ពេលត្រូវសងតាមការព្រមព្រៀងរបស់ភាគីទេ បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀត។ មូលហេតុដែលច្បាប់មិនឱ្យបង្កើតកិច្ចសន្យាបញ្ចាំផ្តាច់នៅមុនកំណត់ពេលត្រូវសង គឺក្នុងគោលបំណងដើម្បីការពារដល់អ្នកបង្កើត សិទ្ធិលើការបញ្ចាំ និងហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំមិនឱ្យទទួលបានផលប្រយោជន៍ច្រើនហួសប្រមាណ។ ផ្ទុយមកវិញ បើកិច្ចសន្យា ឬសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬចាត់ចែងវត្ថុបញ្ចាំ ធ្វើក្រោយពេលកំណត់សងនៃការបញ្ចាំ គឺមិនត្រូវបានហាមឃាត់ទេ ។[4]

បើសិនមិនមានបញ្ញត្តិពិសេសនៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀងឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។[5]

[3] មាត្រា ៨២៦ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[4] ទំព័រទី៣៦ ក្រមរដ្ឋប្បវេណីភាគ៥ បោះពុម្ពនៅក្នុងខែមីនា ឆ្នាំ២០១២

[5] មាត្រា ៨២៧ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងន័យនេះបានហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ក្នុងករណីដែលកាតព្វកិច្ចមិនត្រូវបានសងទេ (ហៅថា កិច្ចសន្យាបញ្ចាំផ្តាច់)។ ហើយបានហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំផងដែរ មិនឱ្យប្តូរវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំឱ្យទៅជាប្រាក់ដោយការអនុវត្តឯកជនឡើយ។ ប៉ុន្តែក្នុងន័យនេះបានទទួលស្គាល់ផងដែរថា ការបញ្ចាំផ្តាច់អាចអនុញ្ញាតតាមរយៈកិច្ចព្រមព្រៀងដោយអនុលោមតាមក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត។ ចំណុចនេះគឺនិយាយអំពីគោលការណ៍ទូទៅ ម៉្យាងទៀតចំពោះសិទ្ធិលើការបញ្ចាំចលនវត្ថុ មានបញ្ញត្តិដែលអនុញ្ញាតឱ្យអនុវត្តដោយសង្ខេប ត្រូវបានចែងដាច់ដោយឡែក។

ឧទាហរណ៍ ៖ លោក វាសនា បានយកផ្ទះដែលមានតម្លៃ ៥ ម៉ឺន ទៅដាក់បញ្ចាំដើម្បីទទួលបានប្រាក់ ៤ ម៉ឺនដុល្លារ ពីលោក ដារា ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ។ ហើយលោក ដារា បានបង្កើតកិច្ចសន្យាបញ្ចាំ ដោយចែងអំពីការដែលលោក វាសនា ពុំមានប្រាក់គ្រប់គ្រាន់ដើម្បីយកមករំលោះវិញទេ លោក វាសនា មានសិទ្ធិផ្តល់ប្រាក់បន្ថែមដើម្បីយកផ្ទះដែលជាកម្មវត្ថុនៃការបញ្ចាំនោះឡើង។ ដូច្នេះក្នុងន័យនេះ ច្បាប់បានហាមឃាត់មិនឱ្យមានការបញ្ចាំផ្តាច់នេះឡើយ កិច្ចសន្យានោះ មិនមានសុពលភាពត្រង់ចំណុចនេះឡើយ។ (នេះជាឧទាហរណ៍ក្នុងន័យទូទៅដែលមិនមានកំណត់ពិសេសនៅក្នុងច្បាប់)

### ១.១.៤ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរំលត់សិទ្ធិលើបំណុលដោយផ្អែកលើការដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់។[6] អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេង។[7]

ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរ ដោយសាលក្រម ឬសាលដីកាស្ថាពរ ឬ ដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង ៥ (ប្រាំ) ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ត្រូវមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំគិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលជាស្ថាពរដែរ។[8]

---

[6] មាត្រា ៤៨០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[7] មាត្រា ៤៨២ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[8] មាត្រា ៤៨៤ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ។[9] ការប្រើសិទ្ធិលើការបញ្ចាំ មានន័យខុសគ្នាពីការអនុវត្តសិទ្ធិលើការបញ្ចាំ ដោយសារការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវចាត់វិធានការដទៃផ្សេងទៀតដើម្បីផ្អាកអាជ្ញាយុកាល ។[10]

## ១.២ សិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ជាទូទៅរាល់ការបញ្ចាំដែលកូនបំណុលបានយកវត្ថុណាមួយ ដើម្បីយកមកធ្វើជាកម្មវត្ថុនៃការបញ្ចាំ ដើម្បីទទួលបានប្រាក់ពីការបញ្ចាំនោះ ម្ចាស់បំណុលគឺមានសិទ្ធិមួយចំនួនលើវត្ថុដែលជាកម្មវត្ថុបញ្ចាំនោះ។ សិទ្ធិនោះរួមមាន ៖ (១) សិទ្ធិកាន់កាប់, (២) សិទ្ធិឃាត់ទុក និង (៣) សិទ្ធិទទួលផលពីកម្មវត្ថុនៃការបញ្ចាំដោយមានអាទិភាព។

### ១.២.១ សិទ្ធិកាន់កាប់

សិទ្ធិកាន់កាប់វត្ថុចំពោះម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំបាន។ ការកាន់កាប់សំដៅទៅលើការក្តាប់ទុកវត្ថុ មានន័យថាជាការគ្រប់គ្រងលើរូបវត្ថុ តាមការជាក់ស្តែង (ការកាន់កាប់ត្រូវបានផ្ទេរដោយការប្រគល់វត្ថុកាន់កាប់) ទោះដោយចំពោះក្តី ឬដោយប្រយោលក្តី (ការកាន់កាប់អាចត្រូវផ្ទេរដោយការព្រមព្រៀងគ្នារវាងងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់ជាក់ស្តែង)។[11] ការកាន់កាប់អាចធ្វើបានដោយប្រយោល តាមរយៈអ្នកដទៃបាន ហើយអាចផ្ទេរការកាន់កាប់ទៅឱ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយនឹងតតិយជន និងដោយការជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកកាន់កាប់ដោយចំពោះ ការធ្វើបែបនេះគេហៅថាការផ្ទេរការកាន់កាប់ដោយបញ្ជា។[12]

សិទ្ធិដែលធ្វើឱ្យការក្តាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់ ដូចជាកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិលើការបញ្ចាំ សិទ្ធិជួល ជាអាទិ៍ ហៅថា សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ។[13] ការកាន់កាប់ ត្រូវរំលត់នៅពេលដែលអ្នកកាន់កាប់ បាត់បង់នូវការក្តាប់ទុកវត្ថុកាន់កាប់។ ប៉ុន្តែ ក្នុងករណីដែលអ្នកកាន់កាប់ត្រូវបានដកហូតនូវការកាន់កាប់ ប្រសិនបើអ្នកនោះទទួលការប្រគល់វត្ថុកាន់កាប់មកវិញ ឬ ធ្វើបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ការកាន់កាប់នោះ មិនត្រូវរំលត់ឡើយ។[14]

[9] មាត្រា ៨២៥ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[10] ចំណុច ៣.៤ ទំព័រ ៣៥ នៃក្រមរដ្ឋប្បវេណីភាគ៥ បោះពុម្ពនៅក្នុងខែ មីនា ឆ្នាំ២០១២

[11] មាត្រា២២៧ និងមាត្រា២២៨ កថាខណ្ឌទី១ និងទី២ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[12] មាត្រា ២២៩ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[13] មាត្រា ២៤១ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[14] មាត្រា ២៣០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ១.២.២ សិទ្ធិឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំ អាចធ្វើការឃាត់ទុកវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះបាន រហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលនោះ។ ប៉ុន្តែសិទ្ធិឃាត់ទុកមិនត្រូវកើតមានឡើយ ប្រសិនបើសិទ្ធិលើបំណុលនោះមិនទាន់ដល់ពេលកំណត់ត្រូវសង។ សិទ្ធិឃាត់ទុកនេះមិនអាចអនុវត្តបានឡើយ ប្រសិនបើការកាន់កាប់នោះបានចាប់ផ្តើមដោយអំពើអនីត្យានុកូល។[15]

ម្ចាស់សិទ្ធិលើបំណុលដែលមានសិទ្ធិឃាត់ទុក ត្រូវកាន់កាប់វត្ថុដែលឃាត់នោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុច្ចរិត។ មិនអាចយកវត្ថុឃាត់ទុកនោះ ទៅប្រើប្រាស់ ឬជួល ឬដាក់ប្រាតិភោគបានទេ បើគ្មានការយល់ព្រមពីសំណាក់កូនបំណុល។ ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុកអាចប្រើប្រាស់វត្ថុដែលឃាត់ទុកបានត្រឹមកម្រិតដែលចាំបាច់ក្នុងការរក្សានូវវត្ថុឃាត់ទុកនោះ។ ប្រសិនបើ ម្ចាស់សិទ្ធិឃាត់ទុកនោះធ្វើផ្ទុយនឹងច្បាប់ កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកនោះបាន។[16]

ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយវិញបាន។ ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយបង្កើតតម្លៃ ចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយទាំងអស់ដែលខ្លួនបានចេញ ឬតម្លៃប្រាក់កំណើនដែលមានអត្ថិភាព តាមការជ្រើសរើសរបស់កម្មសិទ្ធិករបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន។ ប៉ុន្តែតុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន។

ការអនុវត្តសិទ្ធិឃាត់ទុក មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ។ [17] កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកបាន ដោយផ្តល់នូវប្រាតិភោគដ៏សមរម្យ។[18]

### ១.២.៣ សិទ្ធិទទួលផលពីកម្មវត្ថុនៃការបញ្ចាំដោយមានអាទិភាព

ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។ ផលដែលទទួលបាននោះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។[19]

[15] មាត្រា ៧៧៤ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[16] មាត្រា ៧៧៦ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[17] មាត្រា ៧៧៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[18] មាត្រា ៧៧៩ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[19] មាត្រា ៨២២ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧទាហរណ៍ណ ៖ លោក «ក» មានម្ចាស់បំណុលច្រើន ប៉ុន្តែលោក «ក» ចង់បានប្រាក់បន្ថែមទៀត លោក «ក» ក៏បានយកដីចំការស្វាយ មួយកន្លែងមកដាក់បញ្ចាំជាមួយ លោក «ខ» ដើម្បីទទួលបានប្រាក់ ៣,០០០ (បីពាន់) ដុល្លារ ។ ក្នុងអំឡុងពេលដាក់បញ្ចាំនោះ គឺជារដូវដែលទទួលផលពីផ្លែស្វាយបានយ៉ាងច្រើន ដូច្នេះហើយ លោក «ខ» អាចយកផលជាផ្លែស្វាយនោះ ដែលជាផលពីធម្មជាតិដើម្បីលក់ និងលក់យកមកកាត់សិទ្ធិលើបំណុលរបស់ខ្លួនបាន ដោយមានអាទិភាពជាម្ចាស់បំណុលផ្សេងទៀតបាន ដោយម្ចាស់បំណុលផ្សេងទៀតគ្មានសិទ្ធិទទួលផលពីការលក់ស្វាយនោះបានឡើយ។

## ១.៣ កម្មវត្ថុនៃការបញ្ចាំ

បច្ចុប្បន្នក្នុងការប្រកបអាជីវកម្មរបស់ប្រជាជនគ្រប់រូបតែងតែជួបប្រទះនឹងបញ្ហាធ្ងន់ធ្ងរ និងបញ្ហាធូរស្រាល។ ដោយឡែកចំពោះអាជីវករមួយចំនួន ឬប្រជាជនមួយចំនួនត្រូវការដើមទន់ ឬត្រូវការប្រើប្រាស់ប្រាក់ជាបន្ទាន់ ដើម្បីដោះស្រាយវិបត្តិចំពោះមុខ គេអាចដាក់បញ្ចាំទ្រព្យសម្បត្តិអ្វីមួយទៅម្ចាស់បំណុលក្នុងការធានាបំណុល ដោយទទួលបាននូវប្រាក់ពីម្ចាស់បំណុលចំពោះការដាក់បញ្ចាំនោះ។ កម្មវត្ថុនៃការដាក់បញ្ចាំមានដូចជា៖ ការដាក់បញ្ចាំអចលនវត្ថុ ដាក់បញ្ចាំចលនវត្ថុ និងការដាក់បញ្ចាំសិទ្ធិ។

### ១.៣.១ ការដាក់បញ្ចាំអចលនវត្ថុ

ក្នុងគោលការណ៍ច្បាប់បានចែងថា ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចយកវត្ថុបញ្ចាំទៅប្រើប្រាស់ ឬអាស្រ័យផលដោយគ្មានការយល់ព្រមពីកូនបំណុល ដែលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំទេ ចំពោះការប្រើប្រាស់ចលនវត្ថុដាក់បញ្ចាំ គឺត្រូវតែមានការយល់ព្រមពីកូនបំណុលជាដាច់ខាត ដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះម្ចាស់សិទ្ធិលើការបញ្ចាំ ដែលអាចប្រើប្រាស់ និងអាស្រ័យផលបាន គឺក្នុងករណីដែល វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះ គឺជាអចលនវត្ថុ ការប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុនោះ ពុំចាំបាច់មានការយល់ព្រមពីកូនបំណុលឡើយ ។ ឧទាហរណ៍ ៖ លោក ក យកដីកសិកម្មដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនដាក់បញ្ចាំ លោក ខ។ លោក ខ អាចប្រើប្រាស់ និងអាស្រ័យផលលើដីកសិកម្មនោះបានដោយមិនចាំបាច់មានការយល់ព្រមពីលោក ក ទេ។

ទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលក៏ដោយ ប៉ុន្តែការប្រើប្រាស់ និងអាស្រ័យផលនោះ គឺត្រូវគោរពវិធីនៃការប្រើប្រាស់នៃអចលនវត្ថុនោះ ឬសិទ្ធិលើបំណុលដែលគ្មានកំណត់ពេល និងមានកំណត់ពេល។

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំតាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ។ ចំពោះដីដែលម្ចាស់សិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះ ដើម្បីធ្វើកសិកម្ម ទោះ

បីជាសិទ្ធិលើបំណុលរំលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិលើបំណុលបានសាប ឬដាំពីមុន នឹងដល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំក៏ម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះ រហូតដល់ពេលរដូវប្រមូលផលនោះ។ ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរំលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែទោះបីជារដូវប្រមូលផលនោះ នឹងដល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង។[20]

ឧទាហរណ៍ទី១ ៖ ការបញ្ចាំដោយគ្មានពេលកំណត់សង

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១០ លោក ក (កូនបំណុល) បានយកដីប្រភេទកសិកម្មមួយកន្លែងដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ទៅដាក់បញ្ចាំនឹងលោក ខ (ម្ចាស់បំណុល) ដើម្បីធានាបំណុលចំនួន ៣ (បី) ម៉ឺនដុល្លារ។ ក្រោយមកលោក ខ បានយកដីនោះទៅដាំស្វាយ ដែលនឹងអាចទទួលផលនៅក្នុង ៥ (ប្រាំ) ឆ្នាំក្រោយ ។ បន្ទាប់មកនៅចុងឆ្នាំទី៤ លោក ក បានឃើញថាអាចនឹងទទួលផលពីដំណាំនោះ នៅក្នុងឆ្នាំទី៥ ក៏បានយកប្រាក់ចំនួន ៣ (បី) ម៉ឺនដុល្លារមកសងលោក ខ វិញដើម្បីរំលត់សិទ្ធិលើបំណុល។ ក្នុងករណីនេះក្រោយពេលលោក ក បានសងប្រាក់លោក ខ វិញហើយ តើលោក ក នឹងទទួលបានដី ព្រមទាំងដំណាំលើដីនោះវិញដែរឬទេ?

លោក ក បានដាក់ដីបញ្ចាំប្រាក់ ៣ ម៉ឺនដុល្លារ ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន ដោយពុំមានកំណត់រយៈពេលសងឡើយ។ ក្រោយមក លោក ខ ដែលជាម្ចាស់សិទ្ធិលើបំណុល បានយកដីនោះទៅដាំស្វាយ និងគម្រោងដែលអាចនឹងទទួលផលនៅ៥ ឆ្នាំបន្ទាប់។ ស្រាប់តែនៅចុងឆ្នាំទី៤ លោក ក បានយកប្រាក់ ៣ ម៉ឺនដុល្លារទៅសងលោក ខ វិញដើម្បីរំលត់សិទ្ធិលើបំណុលរបស់ខ្លួន។ ក្នុងករណីបែបនេះ លោក ក អាចសងប្រាក់នោះទៅលោក ខ វិញបានដើម្បីរំលត់សិទ្ធិលើបំណុលរបស់ខ្លួន ប៉ុន្តែលោក ក មិនទាន់អាចយកដីនោះមកវិញបានទេ ព្រោះលោក ក បានសងប្រាក់នោះទៅលោក ខ វិញនៅចុងឆ្នាំទី៤ ដែលនឹងសល់រយៈពេលមួយឆ្នាំទៀតប៉ុណ្ណោះដល់ពេលត្រូវប្រមូលផលហើយ។ ដូច្នេះ បើយោងតាមមាត្រា ៨៣៤ សិទ្ធិប្រើប្រាស់នឹងអាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាក្រកម្ពុជា លោក ក ពុំទាន់អាចយកដីនោះត្រឡប់មកវិញបានឡើយ ក្នុងអំឡុងពេលមួយឆ្នាំនៃការប្រមូលផលពីដីនោះ។

[20] មាត្រា៨៣៤ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដូច្នេះលោក ខ មានសិទ្ធិប្រើប្រាស់ដីនោះបន្តរហូតដល់ប្រមូលផលរួច។

ឧទាហរណ៍ទី២ ៖ ការបញ្ចាំដោយមានកំណត់រយៈពេល

លោក ក (កូនបំណុល) មានដីកសិកម្មមួយកន្លែង ដែលអាចដាំដំណាំបានច្រើនប្រភេទ។ នៅចុងឆ្នាំ ២០០៩ លោក ក បានសាងសង់ផ្ទះមួយកន្លែងដែលខ្វះប្រាក់ចំនួន ៥ ម៉ឺនដុល្លារ។ ហើយនៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ លោក ក បានយកដីកសិកម្មដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនទៅដាក់បញ្ចាំ ៥ ម៉ឺនដុល្លារ ជាមួយលោក ខ (ម្ចាស់បំណុល) ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន។ កិច្ចសន្យាបញ្ចាំនោះ បានកំណត់រយៈពេល ៦ ឆ្នាំទើប លោក ក ត្រូវសងប្រាក់បំណុលនោះទៅលោក ខ វិញ។ ក្រោយពីធ្វើកិច្ចសន្យាបញ្ចាំរួចហើយ លោក ខ បានយកដីនោះទៅដាំទុរេនដែលវានឹងអាចហុចផលឱ្យនៅឆ្នាំទី៦។ នៅពេលចុងឆ្នាំទី ៥ លោក ក បានសម្លឹងឃើញពីការប្រមូលផលពីទុរេន និងខ្លួនអាចមានលទ្ធផលសងបំណុលវិញនោះ លោក ក ក៏បានយកប្រាក់ចំនួន ៥ ម៉ឺនដុល្លារ ទៅសងលោក ខ វិញដើម្បីរំលត់សិទ្ធិលើបំណុលមុនកំណត់ពេល ហើយនឹងទាមទារយកដីនោះពីលោក ខ ត្រឡប់មកវិញ។ តើក្រោយពេលរំលត់សិទ្ធិលើបំណុលមុនពេលកំណត់រួច លោក ក មានសិទ្ធិទាមទារដីនោះពីលោក ខ វិញដែរឬទេ?

ម្ចាស់បំណុល បានយកដីនោះទៅដាំទុរេន ដែលនិងអាចហុចផលឱ្យនៅឆ្នាំទី៦។ ដល់ចុងឆ្នាំទី៥ កូនបំណុលបានយកប្រាក់ចំនួន ៥ ម៉ឺនដុល្លារមកសងវិញដើម្បីរំលត់សិទ្ធិលើបំណុល ហើយក៏ទាមទារយកដីនោះត្រឡប់ទៅវិញ។ ក្នុងករណីនេះ ប្រសិនបើ ផលពីទុរេននឹងប្រមូលនៅក្នុងអំឡុងឆ្នាំទី៦ នោះ ទោះបីកូនបំណុលបានរំលត់សិទ្ធិបំណុលមុនកំណត់ពេលក៏ដោយ ក៏ម្ចាស់បំណុលនៅតែអាចប្រើប្រាស់ដីនោះ រហូតដល់ប្រមូលផលរួច ទើបកូនបំណុលមានសិទ្ធិទាមទារដីនោះត្រឡប់ទៅវិញ។ ប៉ុន្តែប្រសិនបើកូនបំណុលសងប្រាក់មុនពេលកំណត់នៅដើមឆ្នាំទី៥ នោះ ហើយការប្រមូលផលពីទុរេននោះនឹងដល់នៅដើមឆ្នាំទី៧ ក្រោយពេលកំណត់ ម្ចាស់បំណុលត្រូវតែសងដីនោះត្រឡប់ទៅកូនបំណុលវិញ។

**ករណីសងមុនពេលកំណត់**






### ១.៣.២ ការដាក់បញ្ចាំចលនវត្ថុ

ការដាក់បញ្ចាំចលនវត្ថុ គឺជាការដាក់បញ្ចាំនូវទ្រព្យសម្បត្តិដែលអាចរំកិលបាន ដោយមិនបាត់បង់សមាសភាពដើម មានដូចជា ៖ យានជំនិះ, ឧបករណ៍អេឡិចត្រូនិច, គ្រឿងសង្ហារឹម និងផ្សេងៗទៀត ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន ក្នុងការទទួលបានប្រាក់ចំពោះការដាក់បញ្ចាំនូវចលនទ្រព្យនោះពីម្ចាស់បំណុល។

បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬជួលវត្ថុបញ្ចាំបានឡើយ។ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បាន ត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ។ បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រព្រឹត្តផ្ទុយនឹងច្បាប់ កូនបំណុលអាចរំលត់សិទ្ធិលើការបញ្ចាំបាន។[21]

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុលជាមុន។ ក្នុងករណីដែលបានកំណត់ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ។[22]

### ១.៣.៣ ការបញ្ចាំសិទ្ធិ

ការបញ្ចាំនេះ មានលក្ខណៈខុសពីការបញ្ចាំចលនវត្ថុ និងការបញ្ចាំអចលនវត្ថុ។ ការបញ្ចាំចលនវត្ថុ និងអចលនវត្ថុ គឺជាការយកទ្រព្យរបស់កូនបំណុលទៅដាក់ធានាបំណុល។ ផ្ទុយទៅវិញ ការបញ្ចាំសិទ្ធិ សំដៅលើការដែលកូនបំណុលយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះកូនបំណុលទី៣ ទៅដាក់បញ្ចាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំរបស់ខ្លួន ដើម្បីធានានូវការសងបំណុលនោះ។

ឧទាហរណ៍ ៖ លោក ក ជាម្ចាស់បំណុលរបស់ លោក គ ចំនួន ២,០០០ ដុល្លារ។ តែលោក ក ចង់ខ្ចីបំណុលពីលោក ខ ចំនួន ១,០០០ ដុល្លារ។ បើសិនជា លោក ក គ្មានទ្រព្យអ្វីផ្សេងយកមកបញ្ចាំឱ្យ លោក ខ ដើម្បីធានាបំណុលទេ លោក ក អាចយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ លោក គ ទៅដាក់បញ្ចាំឱ្យលោកខដើម្បីធានានូវការសងបំណុលដែលខ្លួនមានចំពោះលោកខបាន។[23]

---

[21] មាត្រា៨៣១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មាត្រា៨៣២ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[23] ទំ ៤២ ចំ៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីភាគ ៥ បោះពុម្ព.០២.១២

# ជំពូកទី២

# នីតិវិធីនៃការបង្កើតកិច្ចសន្យា បញ្ចាំអចលនវត្ថុ និងការអនុវត្ត កិច្ចសន្យា

# ជំពូកទី២
# នីតិវិធីនៃការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ និងការអនុវត្តកិច្ចសន្យា

ការបញ្ចាំអចលនវត្ថុ គឺកិច្ចសន្យាមួយក្នុងចំណោមកិច្ចសន្យាជាច្រើនទៀត ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ដែលនិយាយអំពីការបញ្ចាំអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា។ ការបញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាដែលកូនបំណុលប្រគល់អចលនវត្ថុ ដែលជាកម្មវត្ថុនៃការបញ្ចាំឱ្យទៅម្ចាស់បំណុលរបស់ខ្លួនធ្វើការកាន់កាប់ដើម្បីធានាការសងបំណុល។ អចលនវត្ថុសំដៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។ បុគ្គលដែលយកអចលនវត្ថុទៅដាក់បញ្ចាំឈ្មោះថា កូនបំណុល រីឯអ្នកទទួលបញ្ចាំអចលនវត្ថុឈ្មោះថា ម្ចាស់សិទ្ធិលើការបញ្ចាំ។

ការបញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាដែលតាមកិច្ចសន្យានោះ កូនបំណុលប្រគល់ឱ្យម្ចាស់បំណុលរបស់ខ្លួននូវទ្រព្យមួយដើម្បីធានាការសងបំណុល។ បានន័យថា ដើម្បីធានាបំណុលរបស់ខ្លួន ច្បាប់នេះតម្រូវឱ្យកូនបំណុលប្រគល់អចលនវត្ថុ ដែលជាកម្មសិទ្ធិនៃការបញ្ចាំទៅឱ្យម្ចាស់បំណុលជាចាំបាច់។[24]

## ២.១ ការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ

### ២.១.១ លក្ខខណ្ឌទម្រង់

ការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ មិនប្រើទម្រង់លិខិតកិច្ចសន្យាជាលក្ខណៈឯកជនបានទេ។ គឺកិច្ចសន្យាប្រភេទនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមរូបមន្តលិខិតយថាភូតដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ដើម្បីអាចតតាំងជាមួយតតិយជនបាន។ ការមិនចុះបញ្ជីនៅអង្គភាពសុរិយោដីនូវកិច្ចសន្យាបញ្ចាំ បណ្តាលឱ្យថ្លោះសិទ្ធិប្រតិភណ្ឌិក ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមប្តឹងទារសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ។[25]

ដោយឡែក ដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា ដើម្បីអាចបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុបាន កូនបំណុលគ្រាន់តែប្រគល់នូវអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ ទៅឱ្យម្ចាស់បំណុលប៉ុណ្ណោះ ដោយពុំតម្រូវឱ្យធ្វើជាលិខិតយថាភូត និងចុះបញ្ជីនៅអង្គភាពសុរិយោដីឡើយ។ ការប្រើប្រាស់ទ្រព្យដាក់បញ្ចាំដោយម្ចាស់បំណុលអាចជំនួសការសងបំណុលនេះជាការប្រាក់តែមួយមុខ ឬជាប្រាក់ដើម និងការប្រាក់ផងក៏បាន បើសិនមានចែងក្នុងកិច្ចសន្យាបញ្ចាំ។[26]

---

[24] មាត្រា២០៦ កថាខណ្ឌទី១ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[25] មាត្រា២០៨ កថាខណ្ឌទី២ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[26] មាត្រា២០៦ កថាខណ្ឌទី២ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិពីការអនុវត្តដូចគ្នារវាង ការបញ្ចាំអចលនវត្ថុ និងហ៊ីប៉ូតែក ដូចនេះកិច្ចសន្យាបញ្ចាំអចលនវត្ថុនោះ នឹងត្រូវកើតឡើងដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជន ដោយយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ។

## ២.១.២ លក្ខខណ្ឌគ្រឹះ

### ២.១.២.១ ឆន្ទៈក្នុងការបង្កើតកិច្ចសន្យា

គូភាគីបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាដោយមានឆន្ទៈត្រូវរ៉ូវគ្នា។ សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬមុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ។ ស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ ស្វីការត្រូវមានអនុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើនៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬមុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ។[27]

ឧទាហរណ៍ ៖ លោក ក និងលោក ខ មានឆន្ទៈត្រូវរ៉ូវគ្នា និងបង្កើតកិច្ចសន្យាបញ្ចាំដីស្រែមួយកន្លែងដែលជាកម្មសិទ្ធិរបស់លោក ក។ លោក ក បានជូនដំណឹងទៅលោក ខ ចំពោះការបង្កើតកិច្ចសន្យាបញ្ចាំចំនួន ៣ ម៉ឺនដុល្លារ ដែលមានដីស្រែជាកម្មវត្ថុនៃការបញ្ចាំ។ ក្រោយពេលលោក ខ បានទទួលសំណើហើយ គឺមានអានុភាពតែម្តង ហើយប្រសិនបើលោក ខ មានឆន្ទៈយល់ព្រម និងសំណើនោះ បានន័យថា សំណើរនិងស្វីការត្រូវរ៉ូវគ្នា នាំឱ្យការបង្កើតកិច្ចសន្យាបញ្ចាំនោះមានអានុភាព។ ប៉ុន្តែប្រសិនបើលោក ក ចង់ដកសំណើវិញ និងជូនដំណឹងទៅលោក ខ ព្រមគ្នា និងសំណើ ឬមុនពេលសំណើទៅដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតមានឡើយ។

### ២.១.២.២ ការបង្កើតកិច្ចសន្យាដោយមានវិការៈ

ជាទូទៅការបង្កើតកិច្ចសន្យាមួយ មិនថាកិច្ចសន្យាប្រភេទណាទេ ប្រសិនបើបង្កើតឡើងដោយក្រៅឆន្ទៈនោះ គឺភាគីនៃកិច្ចសន្យាអាចលុបចោលបាន។ ការបង្កើតកិច្ចសន្យាក្រៅឆន្ទៈនោះមាន ៖ ការបង្កើតកិច្ចសន្យាដោយការភាន់ច្រឡំ, ការបង្កើតកិច្ចសន្យាដោយការឆបោក, ការបង្កើតកិច្ចសន្យាដោយព័ត៌មានមិនពិត, ការរំលោភបំពានលើស្ថានភាព, ការគម្រាមកំហែង, អំពើកេងយកចំណេញហួសហេតុ, ដោយការគម្រាមកំហែង, ដោយបបនីយផ្លូវចិត្ត, ការបង្ហាញឆន្ទៈមិនពិត និងអលទ្ធភាពតាំងពីដំបូង។

- ការបង្កើតកិច្ចសន្យាដោយការភាន់ច្រឡំ ៖ ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យាបើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងពីការភ័ន្តច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

[27] មាត្រា ៣៣៧ កថាខណ្ឌទី២,៣,៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ។[28]

- ការបង្កើតកិច្ចសន្យាដោយការឆបោក ៖ ក្នុងករណីដែលការបង្ហាញឆន្ទៈ បានធ្វើឡើងដោយសារការឆបោករបស់តតិយជនអ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈលុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬអាចដឹងអំពីការឆបោកនោះ។ ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។[29]
- ការបង្ហាញព័ត៌មានមិនពិត ៖ នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[30] ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។
- ការធ្វើកិច្ចសន្យាដោយការរំលោភបំពានលើស្ថានភាព ៖ នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យា បានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។[31]

[28] មាត្រា៣៤៦ កថាខណ្ឌទី១ និងទី៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[29] មាត្រា៣៤៧ កថាខណ្ឌទី២ និងទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា៣៤៨ កថាខណ្ឌទី១ និងទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[31] មាត្រា៣៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ការគម្រាមកំហែង៖ បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[32]
- អំពើកេងយកចំណេញហួសហេតុ ៖ ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[33]
- បបនីយផ្លូវចិត្ត ៖ ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន។[34]
- ការបង្ហាញឆន្ទៈមិនពិត ៖ កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ។ មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅចំណុចខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែចំណុចនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬមិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយកំហុសធ្ងន់ធ្ងរ ។[35]
- អលទ្ធភាពតាំងពីដំបូង៖ ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ។ ប៉ុន្តែ ចំណុចនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលលក្ខខណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ។ ក្នុងករណីដែលភាគីដែលគួរតែ

[32] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[33] មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[34] មាត្រា៣៥២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[35] មាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អាចដឹងថាអត្ថន័យ នៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាននាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយផ្អែកតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។[36]

### ២.១.៣ មោឃភាព និងការលុបចោល

#### ២.១.៣.១ មោឃភាព

មោឃភាព គឺភាពពុំមានអានុភាពតាមផ្លូវច្បាប់ នៃសកម្មភាពគតិយុត្ត ដែលផ្ទុយនឹងបញ្ញត្តិអំពីនីតិវិធីនៃបណ្តឹង។ ប្រសិនបើអត្ថន័យនៃសកម្មភាព (សំដៅទៅលើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី) ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសេកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមានដោយក្រមនេះ ឬច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។[37]

កិច្ចសន្យាដែលពុំមានអនុភាពតាមផ្លូវច្បាប់ សាច់ញាតិរបស់ភាគីដែលជាអ្នកបង្កើតកិច្ចសន្យាក៏អាចសុំមោឃភាពកិច្ចសន្យានោះបានដែរ ហើយប្រសិនបើមោឃភាពហើយ បានន័យថាកិច្ចសន្យានោះមិនមានអនុភាពតាំងពីដំបូង។

#### ២.១.៣.២ ការលុបចោល

កិច្ចសន្យាអាចលុបចោលបាន ដោយហេតុថាការបង្ហាះឆន្ទៈមានវិការៈ។ ក្នុងករណីដែល មានការភាន់ច្រឡំក្នុងការបង្ហាញឆន្ទៈ ដោយការឆបោក ឬគម្រាមកំហែង ឬភាគីម្ខាងទៀតមិនបង្ហាញការពិត និងដោយមានគោលបំណងគេងចំណេញហួសហេតុ។ សកម្មភាពដែលអាចលុបចោលបាន ៖

- សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។
- ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។
- ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ។[38]

[36] មាត្រា៣៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[37] មាត្រា៣៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38] មាត្រា៣៥៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ នៅក្នុងក្រមរដ្ឋប្បវេណី អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬអ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។ ចំពោះការលុបចោលដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន។ សន្តតិជន ឬអច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។[39]

រយៈពេលនៃការរំលត់សិទ្ធិលុបចោល ៖

- ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និងសិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះត្រូវរំលត់។ បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយចំពោះអំឡុងពេលនេះ។
- ទោះបីមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរំលត់ដែរ។
- ក្នុងករណីដែលបុគ្គលច្រើននាក់មានសិទ្ធិលុបចោលនូវសកម្មភាពតែមួយ បញ្ញត្តិទាំងពីរខាងលើនេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ។[40]

## ២.២ រយៈពេលបញ្ចាំ និងអានុភាព

### ២.២.១ រយៈពេលបញ្ចាំអចលនវត្ថុ

ជាទូទៅកិច្ចសន្យាបញ្ចាំអចលនវត្ថុ អាចធ្វើដោយពុំមានកំណត់ពេលសងក៏បាន អាចធ្វើដោយមានកំណត់ពេលសងក៏បាន។ កិច្ចសន្យាដែលមិនមានកំណត់ពេលសង គឺពេលណាកូនបំណុលសងប្រាក់គ្រប់ទៅម្ចាស់បំណុល និងនាំឱ្យកិច្ចសន្យានោះរំលត់ភ្លាម។ ចំពោះកិច្ចសន្យាដែលមានកំណត់ពេលសងវិញ ទោះបីអាចកំណត់ពេលសងក៏ដោយ ក៏ច្បាប់ពុំអនុញ្ញាតឱ្យយូរពេកដែរ។

អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម៥ (ប្រាំ)

---

[39] មាត្រា៣៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[40] មាត្រា៣៦៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឆ្នាំ។ កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន។ ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ។[41]

ឧទាហរណ៍ ៖ នៅថ្ងៃទី១ ខែ១ ឆ្នាំ២០១០ លោក ក (កូនបំណុល) បានបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុមួយជាមួយលោក ខ (ម្ចាស់បំណុល) ដោយដាក់បញ្ចាំដីស្រែមួយកន្លែងដែលជាកម្មសិទ្ធិរបស់ខ្លួន។ សំណើនៃការដាក់បញ្ចាំគឺចំនួន ៨ ម៉ឺនដុល្លារ ដោយចំនួនលុយច្រើនពេក និងមានការប្រាក់ទាបនោះ កូនបំណុលចង់បង្កើតកិច្ចសន្យាដោយមានអំឡុងពេល ១០ ឆ្នាំតែម្តង។ ក្នុងករណីនេះ កិច្ចសន្យានេះ មិនមានអានុភាពតាមផ្លូវច្បាប់ គឺត្រូវបន្ថយមកត្រឹម ៥ ឆ្នាំ វិញទើបកិច្ចសន្យានេះមានអានុភាព។ ហើយច្បាប់បានបើកទូលាយសម្រាប់ការបន្តកិច្ចសន្យាបញ្ចាំ បន្តរយៈពេល ៥ ឆ្នាំទៀត ដោយគិតចាប់តាំងពីពេលដែលបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុបន្តនោះ។ នៅពេលផុតរយៈពេលនៃកិច្ចសន្យាបញ្ចាំ ដោយកូនបំណុលបានសងប្រាក់អស់វិញក្តី ឬដោយផុតរយៈពេលប្តឹងដូចមានចែងក្នុងមាត្រា២០៩ នៃច្បាប់ភូមិបាលក្តី ម្ចាស់បំណុលត្រូវសងមកកូនបំណុលវិញនូវទ្រព្យ ឬតម្លៃនៃទ្រព្យ ប្រសិនបើទ្រព្យនេះត្រូវបានវិនាសដោយអំពើ ឬកំហុសណាមួយរបស់ម្ចាស់បំណុល។[42] បានន័យថាទោះបីម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យលើអចលនវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាពិតមែន ប៉ុន្តែម្ចាស់បំណុលពុំមានសិទ្ធិចាត់ចែងនោះទេ ប្រសិនបើម្ចាស់បំណុលបានធ្វើឱ្យបាត់បង់នូវអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ ម្ចាស់បំណុលត្រូវសងជាប្រាក់មកកូនបំណុលវិញ។

### ២.២.២ អានុភាពនៃការបញ្ចាំអចលនវត្ថុ

បើកូនបំណុលបានសងបំណុលគ្រប់ចំនួនហើយ ម្ចាស់បំណុលមិនអាចរក្សាទុកទ្រព្យ ដែលបានដាក់បញ្ចាំ ដោយយកលេសថាកូនបំណុលនៅជំពាក់បំណុលមួយផ្សេងទៀតបានទេ ទោះជាបំណុលក្រោយនេះដល់កំណត់ទារហើយក៏ដោយ លើកលែងតែមានកិច្ចសន្យាបញ្ចាំថ្មីមួយទៀតលើទ្រព្យដដែលនេះ ហើយបានរៀបចំតាមទម្រង់នៃច្បាប់ទៀតផង។ កូនបំណុលអាចប្រើសិទ្ធិខាងលើនេះ លើទាយាទ ឬលើសិទ្ធិវន្តនៃម្ចាស់បំណុលបាន។[43] ក្នុងករណីដែលកូនបំណុលបានយកទ្រព្យដែលបានដាក់បញ្ចាំនោះ មានជាប់បំណុលផ្សេងមួយទៀតក៏ដោយ ប្រសិនបើដល់ពេលកូនបំណុលសងបំណុលទី១រួចហើយ ត្រូវតែប្រគល់ទ្រព្យនោះទៅកូនបំណុលវិញ ម្ចាស់បំណុល មិនអាចយកទ្រព្យដដែលនោះ ដើម្បីធានាបំណុលរបស់កូនបំណុលបានឡើយ។ ប៉ុន្តែប្រសិនបើមានកិច្ចសន្យាបញ្ចាំផ្សេងមួយទៀត ដែលមានចែងអំពីការយកទ្រព្យដដែលនោះ ដើម្បីធានាបំណុលរបស់កូនបំណុល។

---

[41] មាត្រា៨៣៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[42] មាត្រា២១៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[43] មាត្រា២១៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១

ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក។[44] ហ៊ីប៉ូតែកមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក និងជាផ្នែកមួយនៃដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ នៅពេលបង្កើតហ៊ីប៉ូតែក រួមទាំងអាគារដែលមាននៅលើដីហ៊ីប៉ូតែកនោះ។ អានុភាពនេះក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតហ៊ីប៉ូតែកផងដែរ។[45] វត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬសំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ឬពូជដែលសាបនៅលើដី ដំណាំដែលបានដាំ រុក្ខជាតិដែលរស់នៅលើដី គឺជាសមាសភាគនៃដី លុះត្រាតែមិនបំបែកចេញពីដី ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ លើកលែងតែមានបញ្ញត្តិផ្សេង។[46]

ការដែលដាក់ទ្រព្យអចលនវត្ថុជាដីដើម្បីដាក់បញ្ចាំ ទោះនៅលើដីនោះ មានផ្ទះ ឬដំណាំ ឬអាគារ ឬសាលារៀនក៏ដោយ ក៏ទ្រព្យនោះគឺជាកម្មវត្ថុនៃការបញ្ចាំដូចគ្នា ព្រោះវាមិនអាចបំបែកចេញពីដីបាន។ ការបំបែកចេញពីដីបាន លុះត្រាតែចលនវត្ថុ ព្រោះការដែលអាចបំបែកចេញពីដីបានគឺសំដៅទៅលើការដែលដកចេញ ហើយមិនធ្វើឱ្យខូចទ្រង់ទ្រាយដើម។

ការដាក់បញ្ចាំអចលនវត្ថុ ទោះបីម្ចាស់សិទ្ធិលើបំណុលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលក៏ដោយ ប៉ុន្តែប្រសិនបើអចលនវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាបញ្ចាំនោះ កំពុងតែផ្តល់ផលដល់កូនបំណុល ក៏កូនបំណុលនៅតែអាចទទួលផលនោះបានដែរ បានន័យថាប្រសិនបើទ្រព្យបញ្ចាំនោះ កូនបំណុលកំពុងតែទទួលផលនោះជារៀងរាល់ខែ គឺកូនបំណុលមានសិទ្ធិទទួលបានផលពីទ្រព្យនោះដដែល ដូចជាផ្ទះជួលដែលមាននៅលើទ្រព្យបញ្ចាំនោះមុនពេលកូនបំណុលយកទ្រព្យនោះទៅដាក់បញ្ចាំ។

## ២.៣ ៖ ការអនុវត្តកិច្ចសន្យាបញ្ចាំអចលនវត្ថុ

### ២.៣.១ សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

នៅក្នុងច្បាប់គេបានកំណត់ថា ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំបាន ហើយមានកាតព្វកិច្ចត្រូវថែរក្សាទ្រព្យបញ្ចាំនោះឱ្យបានត្រឹមត្រូវរហូតដល់ពេលបញ្ចប់នៃកិច្ចសន្យា។

ម្ចាស់បំណុលដែលបានកាន់កាប់ទ្រព្យដាក់បញ្ចាំ អាចមានសិទ្ធិអាស្រ័យផលពីទ្រព្យនោះដូចជាផលុបភោគីដែរ លុះត្រាតែមានចែងក្នុងកិច្ចសន្យាដាក់បញ្ចាំ។ ម្ចាស់បំណុលមានកាតព្វកិច្ចថែទាំរក្សាទុកទ្រព្យនោះឱ្យ

---

[44] មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[45] មាត្រា៨៤៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[46] មាត្រា១២២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដូចជាទ្រព្យរបស់ខ្លួន។ បើទ្រព្យនោះខូចខាតដោយអំពើឬកំហុសណាមួយរបស់ខ្លួន ខ្លួនត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុល ។[47]

### ២.៣.១.១ ផលុបភោគ

ផលុបភោគ សំដៅទៅលើសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយជីវិតរបស់ផលុបភោគី។ ផលុបភោគីមានសិទ្ធិប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ តាមវិធីប្រើប្រាស់ និងមានសិទ្ធិអាស្រ័យផលធម្មជាតិ និងផលស៊ីវិលដែលកើតចេញពីអចលនវត្ថុនោះ។[48]

- **សិទ្ធិអាស្រ័យផលធម្មជាតិ ៖** ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលបង្កើតផលុបភោគ ត្រូវបានទៅលើផលុបភោគី។ ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលផលុបភោគរំលត់ ត្រូវបានទៅកម្មសិទ្ធិករនៃដី។ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះក៏ដោយ ក្នុងករណីដែលមានសិទ្ធិជួលដែលមានអានុភាពតតាំងលើដីដែលជាកម្មវត្ថុនៃផលុបភោគ បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះពុំមានឥទ្ធិពលដល់សិទ្ធិរបស់ភតិកៈនោះក្នុងការអាស្រ័យផលធម្មជាតិឡើយ។ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី២ ខាងលើនេះក៏ដោយ ចំពោះផលធម្មជាតិដែលខ្លួនបានថែទាំរហូតដល់ផលុបភោគរំលត់ ភតិកៈដែលជួលដីពីផលុបភោគីមានសិទ្ធិអាស្រ័យផលធម្មជាតិ។[49]
- **សិទ្ធិអាស្រ័យផលស៊ីវិល ៖** ផលស៊ីវិលត្រូវបានទៅផលុបភោគី តាមសមាមាត្រទៅនឹងអំឡុងពេលដែលផលុបភោគមានអត្ថិភាព។[50]

### ២.៣.១.២ ការបញ្ចាំបន្ត

ក្នុងក្រមរដ្ឋប្បវេណីបញ្ញត្តិនៃមាត្រា ៨៣៩ ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ក្រៅពីបញ្ញត្តិនៃផ្នែកទី៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី៥ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ។[51]

ម្ចាស់បំណុលហ៊ីប៉ូតែកអាចយកហ៊ីប៉ូតែកនេះធ្វើជាប្រាតិភោគសម្រាប់កាតព្វកិច្ចរបស់ខ្លួន ឬតតិយជនបាន។ ករណីនេះហៅថាហ៊ីប៉ូតែកបន្ត។ នៅពេលចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់បានត្រឹម

[47] មាត្រា២១២ នៃច្បាប់ភូមិបាលឆ្នាំ២០០១
[48] មាត្រា២៥៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[49] មាត្រា២៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[50] មាត្រា២៦២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[51] មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កម្រិតនៃចំនួនទឹកប្រាក់នៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក។ ប៉ុន្តែបើសិទ្ធិលើបំណុលនោះមិនទាន់ដល់កំណត់ត្រូវសងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់ចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងនោះប៉ុណ្ណោះ ។[52]

### ២.៣.១.៣ ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល

ទោះបីការដាក់បញ្ចាំអចលនវត្ថុ ធ្វើឱ្យម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យលើវត្ថុនោះពិតមែន ប៉ុន្តែក្នុងករណីដែលមានវិវាទកើតឡើង ម្ចាស់បំណុល មិនអាចមានសិទ្ធិយកទ្រព្យបញ្ចាំធ្វើជាកម្មសិទ្ធិ ឬលក់ទ្រព្យនោះដើម្បីកាត់បំណុលបញ្ចាំនោះបានទេ។ ក្នុងករណីកូនបំណុលមិនព្រមបង់ប្រាក់ដែលជាកាតព្វកិច្ចរបស់ខ្លួនទេនោះ ម្ចាស់បំណុលអាចប្តឹងទៅតុលាការដើម្បីសុំលក់ឡៃឡុងទ្រព្យនោះបាន។

កិច្ចសន្យាបញ្ចាំអចលនវត្ថុ អនុញ្ញាតិឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការឱ្យដាក់លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាព ដោយបុរិមា និងបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត។ បើសិនជាក្នុងរយៈពេលនៃកិច្ចសន្យាបញ្ចាំ ម្ចាស់បំណុលដែលទទួលបញ្ចាំទិញអចលនវត្ថុដែលដាក់បញ្ចាំ កិច្ចសន្យាទិញនេះត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ពុំនោះទេ នឹងត្រូវចាត់ទុកជាមោឃៈ។[53]

#### ក. ការអនុវត្តដោយបង្ខំ និងលក្ខខណ្ឌ

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី។ ស្ថាប័នអនុវត្តគឺតុលាការអនុវត្ត ឬអាជ្ញាសាលា។[54]

របៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ ៖

១.ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

២.នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត។
- សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

[52] មាត្រា៨៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកច្រកម្ពុជា ឆ្នាំ២០០៧

[53] មាត្រា២១១ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[54] មាត្រា៣៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

៣.ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ។[55]

ខ. លិខិតអនុវត្ត

១. ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត។

២. លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ខាងក្រោមនេះ ៖[56]

- សាលក្រម ឬសាលដីកាបង្គាប់ផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ។
- សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។
- ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក។ ប៉ុន្តែចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ។
- ដីការសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។
- ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅច្បាប់។[57]
- លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។
- សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ។[58]
- សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ។[59]

[55] មាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[56] មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[57] កថាខណ្ឌទី១ នៃមាត្រា ៦៦ នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[58] មាត្រា ៣៥២ សាលក្រមអនុវត្តសាលក្រម ឬសាលដីការរបស់តុលាការបរទេស នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។[60]

### គ. ការអនុវត្ត

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ។ ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និងឯកសារខាងក្រោមនេះ ៖

- ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និងក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្តត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។
- ចំពោះដីដែលមិនបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។[61]

### ឃ. លក្ខខណ្ឌនៃការលក់

តុលាការអនុវត្ត ត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត។ នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬអាចសួរសំណួរ ឬទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬតតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន។ អ្នកវាយតម្លៃត្រូវដាក់ជូនតុលាការអនុវត្តជាលាយលក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និងការវាយតម្លៃអចលនវត្ថុនោះ ។[62]

### ង. វិធីលក់

ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។ តុលាការអនុវត្តអាចកំណត់វិធីលក់ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។ ប្រសិនបើលក់តាមវិធី

[59] មាត្រា ៣៥៣ ដីការសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[60] មាត្រា២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[61] មាត្រា៤១៧ កថាខណ្ឌទី២ និងទី៣ នៃក្រមនិតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[62] មាត្រា៤៣០ កថាខណ្ឌទី១, ទី៣, និងទី៥ នៃក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

លក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ។[63]

ច. អានុភាពនៃការលក់

បើតាមដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ (មួយ) ខែចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ។ ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់។ បើអ្នកទិញគឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ អ្នកទិញនោះអាចបង់ថ្លៃលក់ ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការចែកចំណែកនូវកាលបរិច្ឆេទនៃការចែកចំណែកបាន ដោយស្នើសុំទៅតុលាការអនុវត្ត នៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់។ ក្នុងករណីនេះ បើមានសេចក្តីថ្លែងតវ៉ាអំពីចំនួនប្រាក់នៃការចែកចំណែកដែលអ្នកទិញត្រូវទទួល អ្នកទិញត្រូវបង់ចំនួនប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះជាបន្ទាន់។ អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ ។[64]

## ២.៣.២ ភាតព្វកិច្ចរបស់ម្ចាស់បំណុល

### ២.៣.២.១ ភាតកិច្ចប្រគល់វត្ថុបញ្ចាំ

ទ្រព្យជាប់កិច្ចសន្យាបញ្ចាំអចលនវត្ថុនឹងត្រូវសងមកកូនបំណុលវិញជាចាំបាច់ ចាប់ពីពេលដែលកូនបំណុលបានសងបំណុលទាំងស្រុងរួចហើយ ។ ចំពោះកិច្ចសន្យាដែលមិនបានបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់សងក្នុងរយៈពេល១០ (ដប់) ឆ្នាំគិតពីថ្ងៃដែលបានចុះកិច្ចសន្យាបញ្ចាំមក បើម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារឱ្យសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ ។

ការបាត់បង់ការធានានៃការដាក់បញ្ចាំនេះ តម្រូវឱ្យម្ចាស់បំណុលប្រគល់អចលនវត្ថុ និងប័ណ្ណឱ្យកូនបំណុលវិញ តែកូនបំណុលពុំបានរួចពីការសងបំណុលឡើយ ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមប្តឹងទារសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ។ ការលើកលែងបញ្ចាំ ឬការលុបចោលបន្ទុកបញ្ចាំត្រូវធ្វើលេខាចារិកក្នុងបញ្ជីសុរិយោដីតាមការស្នើសុំរបស់កូនបំណុល ឬដោយឯកឯង។[65]

[63] មាត្រា៤៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[64] មាត្រា៤៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[65] មាត្រា២០៩ កថាខណ្ឌទី១, ទី២, ទី៤ និងទី៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១

#### ២.៣.២.២ ថែរក្សា ឬចេញសោហ៊ុយ

ម្ចាស់បំណុលមានកាតព្វកិច្ចថែទាំរក្សាទុកទ្រព្យនោះឱ្យដូចជាទ្រព្យរបស់ខ្លួន។ បើទ្រព្យនោះខូចខាតដោយអំពើ ឬកំហុសណាមួយរបស់ខ្លួន ខ្លួនត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុលបាន។ [66] ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និងត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ។[67]

ក្នុងន័យនេះគឺម្ចាស់បំណុលត្រូវមើលថែទ្រព្យបញ្ចាំដែលកូនបំណុលបានដាក់បញ្ចាំនោះ ឱ្យដូចជាទ្រព្យរបស់ខ្លួនឯង បើខ្លួនក្នុងនាមជាម្ចាស់បំណុលបានធ្វើឱ្យខូចខាតនោះ ខ្លួនអាចកាត់ជាមួយនិងបំណុលដែលកូនបំណុលបានជំពាក់បាន។

ប្រសិនបើមានការសន្យាគ្នានៅពេលបង្កើតកិច្ចសន្យា អ្នកបង្កើតសិទ្ធិលើការបញ្ចាំ យល់ព្រមឱ្យម្ចាស់បំណុលរួចផុតពីការចេញសោហ៊ុយ ឬបន្ទុកផ្សេងៗទៀត និងអនុញ្ញាតឱ្យម្ចាស់បំណុលទទួលការប្រាក់នៃសិទ្ធិលើបំណុល ទោះជាម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុនោះក៏ដោយ ក៏ការព្រមព្រៀងនោះមានអានុភាពហើយត្រូវយកមកអនុវត្តដែរ។

ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន។ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬសងនូវតម្លៃប្រាក់ដែលកើននោះវិញតាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន។ ប៉ុន្តែតុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន។[68]

### ២.៣.៣ សិទ្ធិ និងកាតព្វកិច្ចនៃអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

នៅពេលដែលបង្កើតកិច្ចសន្យាបញ្ចាំរួចហើយ កូនបំណុលត្រូវតែប្រគល់ទ្រព្យបញ្ចាំទៅម្ចាស់បំណុលដើម្បីធានាបំណុលរបស់ខ្លួន។ ហើយកូនបំណុលមានសិទ្ធិទទួលបានប្រាក់ ដែលជាថ្នូរនឹងការដាក់បញ្ចាំពីម្ចាស់សិទ្ធិលើការបញ្ចាំ។ កូនបំណុលក៏នៅតែមានសិទ្ធិទទួលផលក្នុងទ្រព្យដែលខ្លួនបានដាក់បញ្ចាំ។

ឧទាហរណ៍ ៖ កូនបំណុលបានយកដីមួយកន្លែងដែលបានសាងសង់ដើម្បីធ្វើជាបន្ទប់ជួលទៅដាក់បញ្ចាំ។ ក្នុងករណីនេះ កូនបំណុលក៏នៅតែមានសិទ្ធិទទួលផលពីការជួលបន្ទប់នោះដដែល។

---

[66] មាត្រា២១២ កថាខណ្ឌទី២ និងទី៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[67] មាត្រា៨៣៥ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[68] មាត្រា៨២៤ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្រោយពេលបានដាក់បញ្ចាំទ្រព្យដើម្បីធានាបំណុលរបស់ខ្លួនហើយ កូនបំណុលត្រូវមានកាតព្វកិច្ចបង់ប្រាក់ជារៀងរាល់ខែឱ្យទៅម្ចាស់បំណុល អាស្រ័យលើការចរចារគ្នា អំពីនីតិវិធីនៃការបង់ប្រាក់។ ក្នុងនីតិវិធីនេះ កូនបំណុលមានសិទ្ធិស្នើសុំទៅម្ចាស់បំណុល អំពីការបង់តែការប្រាក់ឱ្យទៅម្ចាស់បំណុលរហូតដល់ពេលបញ្ចប់កិច្ចសន្យា ទើបបង់ប្រាក់ដើម ឬក៏អាចបង់ទាំងការ បង់ទាំងប្រាក់ដើមទៅម្ចាស់បំណុល អាស្រ័យទៅលើថាម្ចាស់សិទ្ធិលើការបញ្ចាំយល់ព្រមពីលក្ខខណ្ឌនេះឬអត់។ ប៉ុន្តែលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងកិច្ចសន្យា ត្រូវតែធ្វើឡើងដោយមានឆន្ទៈត្រូវរូវគ្នា រវាងភាគីទាំងពីរ បើពុំដូច្នេះទេ កិច្ចសន្យាដែលកើតឡើងដោយការមានវិការៈនៃការបង្ហាញឆន្ទៈបែបនេះ មិនមានអានុភាពតាមផ្លូវច្បាប់ទេ។

# ជំពូកទី៣

# ការរំលត់កាតព្វកិច្ចនៃការបញ្ចាំអចលនវត្ថុ

# ជំពូកទី៣

# ការរំលត់ភាគព្វកិច្ចនៃការបញ្ចាំអចលនវត្ថុ

## ៣.១ មូលហេតុនៃការរំលត់ភាគព្វកិច្ច

### ៣.១.១ ការសង

ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន។ ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល។ ម្ចាស់បំណុល និងកូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលការសងដោយតតិយជនបាន។[69]

ម្ចាស់បំណុលមិនមានករណីកិច្ចទទួលការសងមួយភាគនៃកាតព្វកិច្ចទេ។ ប៉ុន្តែក្នុងករណីដែលម្ចាស់បំណុលបានទទួល ដោយដឹងថាជាការសងមួយភាគ ការសងនោះមានសុពលភាពត្រឹមទំហំដែលបានសង។[70]

ក្នុងករណីដែលកូនបំណុលបានផ្តល់តាវកាលិកផ្សេងពីតាវកាលិកដែលជាបន្ទុកដើមរបស់ខ្លួនជាជំនួសវិញ ដោយទទួលការយល់ព្រមពីម្ចាស់បំណុល តាវកាលិកនោះមានអានុភាពដូចគ្នានឹងការសងដែរ។ ម្ចាស់បំណុល និងកូនបំណុលអាចធ្វើការព្រមព្រៀងគ្នាលើតាវកាលិកផ្សេងជំនួសតាវកាលិកដើមបាន។ ក្នុងករណីនេះ កូនបំណុលអាចសងដោយជ្រើសរើសតាវកាលិកដើម ឬតាវកាលិកដោយយកវត្ថុផ្សេងជាជំនួសបាន លើកលែងតែករណីម្ចាស់បំណុលមានសិទ្ធិជ្រើសរើស។[71]

ការសងនឹងមានសុពលភាព លុះត្រាតែធ្វើចំពោះម្ចាស់បំណុល ឬអ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង។ បើកូនបំណុលបានសងដល់អ្នកដែលមានសិទ្ធិទទួលការសង កូនបំណុលនោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀត តាមការទាមទារពីម្ចាស់បំណុលនោះ។ ក្នុងករណីនេះ អ្នកសងអាចទាមទារឱ្យអ្នកគ្មានសិទ្ធិដែលទទួលបានការសងនោះ ប្រគល់កម្មវត្ថុនៃការសងមកវិញបាន។[72]

ក្នុងន័យនេះ ចង់សំដៅដល់តតិយជនដែលចង់សងបំណុលជំនួសកូនបំណុលនោះ អាចធ្វើទៅបានលុះត្រាមានការយល់ព្រមពីម្ចាស់បំណុល។ ហើយការសងប្រាក់អាចសងបានទៅម្ចាស់បំណុល និងអ្នកដែលទទួលសិទ្ធិទទួលការសងតែប៉ុណ្ណោះ កូនបំណុល ឬតតិយជន មិនអាចសងប្រាក់នោះទៅសាច់ញាតិ ឬអ្នកពាក់ព័ន្ធផ្សេងដែលពុំមានសិទ្ធិទទួលការសងដូចគ្នានឹងម្ចាស់បំណុលឡើយ។ ប៉ុន្តែប្រសិនបើកូនបំណុល ឬតតិ-

[69] មាត្រា៤៣៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[70] មាត្រា៤៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[71] មាត្រា៤៤២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[72] មាត្រា៤៣៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

យជនបានសងទៅអ្នកដែលមិនមានសិទ្ធិទទួលបានការសងនោះទេ កូនបំណុល ឬតតិយជននោះអាចទាមទារបំណុលនោះពីអ្នកដែលគ្មានសិទ្ធិទទួលការសងបាន។

កូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ច និងតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។[73] កូនបំណុលត្រូវសងនៅក្នុងម៉ោងធ្វើការធម្មតា តាមទំនៀមទម្លាប់ និងគោលការណ៍នៃភាពសុច្ចរិត និងភាពស្មោះត្រង់។[74]

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីទីកន្លែងដែលត្រូវសងទេ ការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវធ្វើឡើង នៅទីកន្លែងដែលវត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើបំណុលកើតឡើង។ ចំពោះកាតព្វកិច្ចក្រៅពីនេះ ការសងត្រូវធ្វើឡើងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល។[75]

ឧទាហរណ៍ទី១ ៖ លោក «ក» បានជំពាក់ប្រាក់លោក «ខ» ចំនួន ២ ម៉ឺនដុល្លារដែលបានខ្ចី ដោយដាក់អចលនវត្ថុរបស់ខ្លួន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន។ ក្រោយមកលោក «ក» គ្មានប្រាក់សង ក៏ត្រូវបានបងប្អូនសាច់ញាតិជាអ្នកសងជំនួស។ ដើម្បីឱ្យការសងនេះអាចរំលត់កាតព្វកិច្ចបាន លុះត្រាតែការសងនេះត្រូវទទួលបានការយល់ព្រមពីម្ចាស់បំណុល។

ឧទាហរណ៍ទី២ ៖ លោក «ក» ជំពាក់ប្រាក់លោក «ខ» ចំនួន ៥ ម៉ឺនដុល្លារ ក្រោយមកលោក«ក» ចង់រំលត់បំណុលរបស់ខ្លួនវិញ ក្នុងករណីនេះលោក«ក» ត្រូវតែសងប្រាក់នោះទៅម្ចាស់បំណុលដោយផ្ទាល់ទើបកាតព្វកិច្ចនោះត្រូវបានរំលត់។ ហើយកាតព្វកិច្ចនេះមិនអាចរំលត់បានទេក្នុងករណីដែលកូនបំណុលបានសងប្រាក់នោះទៅសាច់ញាតិរបស់លោក «ខ»។

### ៣.១.២ ការទូទាត់

ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នា ចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមក ដោយយកចំនួនប្រាក់ស្មើគ្នាដោយបង្ហាញឆន្ទៈឯកតោភាគី។

គូភាគីអាចធ្វើកិច្ចសន្យាទូទាត់ដែលរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ។ ប៉ុន្តែគូភាគីមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិ-យជនបានឡើយ។[76]

---

[73] មាត្រា៤៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[74] មាត្រា៤៤៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[75] មាត្រា៤៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[76] មាត្រា៤៦៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាង ទៅភាគីម្ខាងទៀត។ ការបង្ហាញឆន្ទៈទូទាត់ អាចដាក់លក្ខខណ្ឌបង្អង់បាន តែមិនអាចដាក់លក្ខខណ្ឌរំលាយ ឬកំណត់ពេលបានឡើយ។[77]

ក្នុងករណីដែលលក្ខខណ្ឌត្រូវបានបំពេញ ហើយនៅពេលឆន្ទៈទូទាត់ត្រូវបានបង្ហាញ អានុភាពដែលរំលត់កាតព្វកិច្ចដោយការទូទាត់ ត្រូវកើតឡើងដោយមានប្រតិសកម្ម តាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របទៅនឹងការទូទាត់។[78]

ក្នុងករណីដែលលក្ខណៈនៃកាតព្វកិច្ចណាមួយ ឬទាំងពីរ មិនអនុញ្ញាតឱ្យធ្វើការទូទាត់ទេ គូភាគីមិនអាចទូទាត់បានទេ។ ក្នុងករណីដែលភាគីទាំងសងខាងធ្វើការសន្យាពិសេសមិនធ្វើការទូទាត់ កូនបំណុលនីមួយៗមិនអាចទូទាត់បានទេ។ ប៉ុន្តែការសន្យាពិសេសមិនធ្វើការទូទាត់នេះ មិនអាចអះអាងចំពោះតតិយជនសុចរិតបានឡើយ។[79]

ក្នុងករណីដែលភាគីម្ខាង ឬទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បានអ្នកសុំទូទាត់ អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និងកាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀតដើម្បីរំលត់ដោយការទូទាត់នោះបាន។ បញ្ញត្តិស្ដីពីការកាត់បំណុលដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទូទាត់ដែលគ្មានការជ្រើសរើស ដូចកំណត់ក្នុងវាក្យខណ្ឌទី១ នៃមាត្រានេះ។[80]

### ៣.១.៣ ការលើកលែង និងការរំលត់កាតព្វកិច្ចដោយអលទ្ធភាព

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវរំលត់។[81] ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន។[82]

បើការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាព ហើយកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាពនោះ កាតព្វកិច្ចត្រូវរំលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ។[83]

### ៣.១.៤ ការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច មានដូចខាងក្រោមនេះ ៖

---

77 មាត្រា៤៦៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

78 មាត្រា៤៦៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

79 មាត្រា៤៦៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

80 មាត្រា៤៧២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

81 មាត្រា៤៧៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

82 មាត្រា៤៧៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

83 មាត្រា៤១៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក. កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលកំណត់ត្រូវអនុវត្ត ដោយសារការយឺតយ៉ាវក្នុងការអនុវត្ត។

ខ. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច។

គ. កូនបំណុលមិនបានអនុវត្តឱ្យបានពេញលេញ តាមខ្លឹមសារនៃកាតព្វកិច្ច។

ឃ. ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។[84]

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្តល់តាវកាលិកមិនពេញលេញ ឬ ករណីដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬករណីផ្សេងទៀតដែលគ្មានការអនុវត្តឱ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច។[85]

### ៣.១.៥ ផុតអាជ្ញាយុកាល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរំលត់សិទ្ធិលើបំណុលដោយផ្អែកលើការដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមរដ្ឋប្បវេណី។ ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកាស្ថាពរ ឬ ដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង៥ (ប្រាំ) ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ត្រូវមានអំឡុងពេល៥ (ប្រាំ) ឆ្នាំគិតពីពេលដែលបំណុលនោះចូលជាស្ថាពរដែរ។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានផ្អាកក្នុងករណីដូចតទៅ ៖

ក.ទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល។

ខ. សកម្មភាពអនុវត្តដោយបង្ខំ ឬសកម្មភាពចាត់ចែងការរក្សាការពារ។

គ. ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេង។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាក និងចាប់ផ្តើមគិតជាថ្មីម្តងទៀត ក្រោយពីហេតុនៃការផ្អាកបានចប់។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការនឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត បន្ទាប់ពីសេចក្តីសម្រេចចូលជាស្ថាពរ។[86]

---

84 មាត្រា៣៨៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

85 មាត្រា៣៩៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.១.៦ នវកម្ម

នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុលដែលរំលត់កាតព្វកិច្ចដើម និងបង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ។ នៅពេលកិច្ចសន្យានវកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ បង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរំលត់។

ប្រសិនបើកាតព្វកិច្ចថ្មីដែលត្រូវបានបង្កើតឡើងដោយនវកម្ម មិនបានបង្កើតអានុភាពដោយសារមូលហេតុដែលកូនបំណុលនៃកាតព្វកិច្ចចាស់មិនអាចព្យាករបាន ឬ ប្រសិនបើកាតព្វកិច្ចថ្មីនោះជាអលទ្ធភាពក្នុងការអនុវត្តតាំងពីដើម នោះកាតព្វកិច្ចដើមមិនត្រូវរំលត់ឡើយ។[87]

### ៣.១.៧ ព្យាកុលភាព

ព្យាកុលភាពសំដៅទៅលើ ករណីដែលកម្មសិទ្ធិ ឬសិទ្ធិប្រត្យក្សផ្សេងទៀត ដែលមានលើវត្ថុតែមួយធ្លាក់ទៅលើបុគ្គលតែម្នាក់ ឬករណីដែលសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀត ដែលមានកម្មវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់។ មធ្យោបាយរំលត់កាតព្វកិច្ច ដែលជនម្នាក់ប្រមូលឱ្យមូលមកលើដៃខ្លួនតែម្នាក់នូវគុណភាពជាម្ចាស់បំណុលផង និងកូនបំណុលផង។

ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរំលត់ដោយព្យាកុលភាព។[88]

## ៣.២ លក្ខណៈដូចគ្នា និងខុសគ្នារវាងហ៊ីប៉ូតែក ជាមួយការបញ្ចាំអចលនវត្ថុ

ហ៊ីប៉ូតែកគឺជារបបគតិយុត្តមួយនៃការធានាបំណុលដោយវត្ថុដែលត្រូវបានដាក់ប្រតិភោគ (ទ្រព្យដាក់ធានាកាតព្វកិច្ចដោយកូនបំណុល)។ សារៈប្រយោជន៍នៃហ៊ីប៉ូតែកគឺ កូនបំណុលមិនចាំបាច់ផ្ទេរការកាន់កាប់ទ្រព្យដែលជាកម្មវត្ថុនៃការបង្កើតហ៊ីប៉ូតែកឱ្យទៅម្ចាស់បំណុលឡើយ មានន័យថា កូនបំណុលនៃហ៊ីប៉ូតែកនៅតែមានសិទ្ធិបន្តការរស់នៅ ឬប្រកបកិច្ចការអាជីវកម្មលើទ្រព្យរបស់ខ្លួនដដែល។

ចំណែកឯការបញ្ចាំអចលនវត្ថុវិញ កូនបំណុលត្រូវយកអចលនទ្រព្យរបស់ខ្លួនទៅដាក់ដើម្បីធានាបំណុលរបស់ខ្លួន ហើយត្រូវផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុបញ្ចាំនោះ ទៅឱ្យម្ចាស់បំណុល ហើយម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើទ្រព្យនោះផងដែរ។

[86] មាត្រា៤៨០, ៤៨១, ៤៨២, កថាខណ្ឌទី១៤៨៤, ៤៨៩, និងមាត្រា៤៩៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[87] មាត្រា៤៧៦ និងមាត្រា៤៧៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[88] មាត្រា៤៧៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

អ្នកខ្ចីប្រាក់ពីធនាគារតែងយល់ច្រឡំថា ការដែលខ្លួនយកទ្រព្យទៅដាក់ធានាបំណុលនៅធនាគារនោះ គឺជាការដាក់បញ្ចាំ ប៉ុន្តែជាក់ស្តែង ការយកប្លង់អចលនទ្រព្យទៅធានាបំណុលជាមួយធនាគារមិនមែនជាការបញ្ចាំទេ គឺជាការដាក់ហ៊ីប៉ូតែក។

ការដាក់ហ៊ីប៉ូតែក និងសិទ្ធិលើការដាក់បញ្ចាំ គឺម្ចាស់បំណុលមានសិទ្ធិទទួលការសង ចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬតតិយជនមិនផ្ទេរការកាន់កាប់។ វាជាកិច្ចសន្យានៃការធានា ដោយកូនបំណុលបានយកទ្រព្យរបស់ខ្លួនដើម្បីធានាកាតព្វកិច្ចដែលមានចំពោះម្ចាស់បំណុល ដោយមិនមានការផ្ទេរការកាន់កាប់អចលនវត្ថុនោះទៅឱ្យម្ចាស់បំណុលឡើយ តែតម្រូវឱ្យមានការចុះបញ្ជីទើបការបង្កើតហ៊ីប៉ូតែកនោះមានអានុភាព។

ការបញ្ចាំអចលនទ្រព្យ គឺខុសពីហ៊ីប៉ូតែក ព្រោះក្នុងករណីបញ្ចាំ ម្ចាស់បំណុលមានសិទ្ធិកាន់កាប់ និងប្រើប្រាស់ទ្រព្យនោះ ប៉ុន្តែក្នុងករណីហ៊ីប៉ូតែកវិញ ម្ចាស់បំណុលគ្មានសិទ្ធកាន់កាប់ និងប្រើប្រាស់ទេ។[89]
ឧទាហរណ៍ ៖ ការដែលកូនបំណុលយកប្លង់ផ្ទះ ឬប្លង់តូបយកទៅដាក់នៅធនាគារដើម្បីធានាបំណុលរបស់ខ្លួន គឺមិនមែនជាការដាក់បញ្ចាំនោះទេ ប៉ុន្តែគឺជាការដាក់ហ៊ីប៉ូតែក។ ខាងក្រោមនេះគឺជាមានលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នាដោយលម្អិត រវាងហ៊ីប៉ូតែក និងការបញ្ចាំ ៖

### ៣.២.១ លក្ខណៈដូចគ្នា

- **កម្មវត្ថុធានា៖** អចលនវត្ថុដែលអាចដាក់បញ្ចាំ ឬដាក់ហ៊ីប៉ូតែកបាន លុះត្រាតែបានចុះបញ្ជីនៅអង្គភាពសុរិយោដី។
- **ការចុះបញ្ជីទ្រព្យដាក់ធានា៖** កិច្ចសន្យាបញ្ចាំ ឬហ៊ីប៉ូតែកអចនវត្ថុ គឺតម្រូវឱ្យធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សររវាងគូភាគី និងត្រូវយកប្លង់ដី ឬប្លង់ផ្ទះនោះទៅឱ្យរដ្ឋបាលសុរិយោដីចារថា ដាក់បញ្ចាំ ឬដាក់ហ៊ីប៉ូតែក ឱ្យទៅបុគ្គលណាមួយ។
- **ការដាក់លក់ដោយបង្ខំ៖** ក្នុងករណីដែលកូនបំណុលមិនអាចសងបំណុលបាន នោះម្ចាស់បំណុលអាចប្ដឹងទៅតុលាការឱ្យដាក់លក់អចលនវត្ថុនោះដោយបង្ខំបាន ដើម្បីយកប្រាក់មកកាត់កងបំណុលនោះ។ ប៉ុន្តែម្ចាស់បំណុលមិនអាចលក់ទ្រព្យធានានោះដោយឯកតោភាគីបានទេ។
- **ការរំលត់នៃកិច្ចសន្យា៖** នៅពេលដែលកូនបំណុលបានសងគ្រប់ចំនួនទៅម្ចាស់បំណុល នោះកិច្ចសន្យាបញ្ចាំ ឬហ៊ីប៉ុតែក ត្រូវរំលត់ដូចគ្នា តែត្រូវយកប្លង់ទៅលុបសិទ្ធិនៅរដ្ឋបាលសុរិយោដី។

[89] បើយោងតាមមាត្រា៨១៦ និង៨៤៣ ក្រមរដ្ឋប្បវេណី

### ៣.២.១ លក្ខខណៈខុសគ្នា

- **សិទ្ធិលើអចលនវត្ថុជាទ្រព្យធានា៖** ចំពោះការបញ្ចាំ ម្ចាស់បំណុលមានសិទ្ធិកាន់កាប់ទ្រព្យបញ្ចាំ ព្រមទាំងអាចទទួលបានផលប្រយោជន៍ដែលមានលើដី ឬផ្ទះនោះផងដែរ។ ប៉ុន្តែចំពោះហ៊ីប៉ូតែកវិញ ម្ចាស់បំណុលមិនអាចកាន់កាប់ទ្រព្យធានាទេ ហើយម្ចាស់កម្មសិទ្ធិ នៅតែអាចប្រើប្រាស់ និងទទួលបានផលប្រយោជន៍ពីដី ឬផ្ទះ របស់ខ្លួនជាប្រក្រតី។
- **ការកំណត់ការប្រាក់៖** ការបញ្ចាំមិនតម្រូវឱ្យយកការប្រាក់ទេ ព្រោះម្ចាស់បំណុលអាចកាន់កាប់ និងអាស្រ័យផលពីទ្រព្យនោះរួចទៅហើយ។[90] ឧទាហរណ៍ បើជាដីចំការ ម្ចាស់បំណុលអាចប្រមូលផលពីចម្ការនោះ ជំនួសការប្រាក់ទៅហើយ។ ប៉ុន្តែមាត្រា៨៣៧ នៃក្រមរដ្ឋប្បវេណី ក៏បានអនុញ្ញាតឱ្យយកការប្រាក់ដែរក្នុងករណីម្ចាស់បំណុលត្រូវចំណាយលើការគ្រប់គ្រងទ្រព្យបញ្ចាំ ជាជាងទទួលបានផលប្រយោជន៍។ ដោយឡែកសម្រាប់ហ៊ីប៉ូតែកវិញ កិច្ចសន្យាត្រូវបញ្ជាក់យ៉ាងច្បាស់ពីប្រាក់ដើម ការប្រាក់ និងប្រាក់ធនលាភផ្សេងៗ។
- **ការកំណត់ថេរវេលា ៖** អចលនវត្ថុមួយ អាចដាក់បញ្ចាំត្រឹម ០៥ ឆ្នាំប៉ុណ្ណោះ ហើយបន្តបានមិនលើសពី ០៥ ឆ្នាំទៀត។ ដោយឡែកសម្រាប់ហ៊ីប៉ូតែកវិញ មិនកំណត់រយៈពេលនោះទេ។ ហ៊ីប៉ូតែកនិងរលត់នៅពេលកូនបំណុលសងបំណុលចប់សព្វគ្រប់។
- **ចំនួនម្ចាស់បំណុល ៖** ការដាក់បញ្ចាំ គឺអាចដាក់បានជាមួយម្ចាស់បំណុលតែម្នាក់ប៉ុណ្ណោះ ប៉ុន្តែម្ចាស់បំណុលអាចយកទ្រព្យទៅបញ្ចាំបន្តបាន។ ប៉ុន្តែសម្រាប់ហ៊ីប៉ូតែកវិញ គឺអាចធ្វើបានជាមួយម្ចាស់បំណុលច្រើននាក់។[91]

សារៈសំខាន់ការដាក់ហ៊ីប៉ូតែក គឺកូនបំណុលមិនបាច់ផ្ទេរនូវការកាន់កាប់ទ្រព្យដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះទៅឱ្យម្ចាស់បំណុលឡើយ។ តាមរយៈការដាក់ហ៊ីប៉ូតែក កូនបំណុលនៅតែអាចបន្តការរស់នៅ ឬការធ្វើអាជីវកម្មនៅលើអចលនវត្ថុនោះបានជាធម្មតា។ មួយវិញទៀត កូនបំណុលនៅតែអាចបង្កើតហ៊ីប៉ូតែកច្រើនលើទ្រព្យតែមួយនោះបាន ជាមួយនឹងម្ចាស់បំណុលច្រើនគ្នាផ្សេងទៀតបាន ដែលលំដាប់នៃការសងបំណុលអាស្រ័យលើពេលនៃការចុះបញ្ជីសុរិយោដីនៃហ៊ីប៉ូតែកនោះ។

ឧទាហរណ៍៖ បុគ្គល ខ ជាម្ចាស់បំណុលរបស់បុគ្គល ក ចំនួន ១០០០ ដុល្លារ ដោយបុគ្គល ក នេះបានយកដីទៅដាក់ហ៊ីប៉ូតែកឱ្យបុគ្គល ខ ដើម្បីធានាបំណុលរបស់ខ្លួន។ ប៉ុន្តែ បុគ្គល ក ក៏មានម្ចាស់បំណុលផ្សេងទៀតគឺ គ និង ឃ។ បើដល់ពេលកំណត់សងហើយ កូនបំណុល ក មិនមានប្រាក់សងនោះទេ ម្ចាស់បំណុល ខ

[90] មាត្រា៨៣៦ នៃក្រមរដ្ឋប្បវេណី

[91] យោងតាមមាត្រា៨៥១ នៃក្រមរដ្ឋប្បវេណី

អាចអនុវត្តសិទ្ធិហ៊ីប៉ូតែកលើដីរបស់កូនបំណុល ក បាន។ តាមរយៈការវាយតម្លៃដីដែលបានដាក់ហ៊ីប៉ូតែកនោះមានតម្លៃលក់បាន ១០០០ ដុល្លារ ដូច្នេះប្រាក់ដែលលក់ដីបាននេះ ត្រូវសងតែចំពោះម្ចាស់បំណុល ខ ប៉ុណ្ណោះ។ ចំណែកឯ គ និង ឃ មិនទទួលបានចំណែកពីការលក់ដីដែលបានដាក់ហ៊ីប៉ូតែកនេះឡើយ។

សរុបមកការដាក់ហ៊ីប៉ូតែកត្រូវបានគេធ្វើញឹកញាប់ជាងការដាក់បញ្ចាំ ព្រោះការដាក់ហ៊ីប៉ូតែកធ្វើឱ្យកូនបំណុលទទួលបាននូវផលប្រយោជន៍ជាច្រើន ដូចជាកូនបំណុលអាចប្រើប្រាស់ទ្រព្យនោះ ដើម្បីអាស្រ័យផល បើសិនទ្រព្យនោះអាចជួលបាន កូនបំណុលអាចដាក់ជួលទ្រព្យដាក់ហ៊ីប៉ូតែកនោះបន្ត ដោយឡែកបើសិនដាក់បញ្ចាំវិញ កូនបំណុលខាតផលប្រយោជន៍ច្រើនចំពោះការដែលមិនអាចប្រើប្រាស់ទ្រព្យរបស់ខ្លួនបានហើយមិនអាចអាស្រ័យផលលើទ្រព្យរបស់ខ្លួនបាន។

# សេចក្ដីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់បំផុត ក៏ដូចជាការសរសេរយ៉ាងលម្អិតជាប់ទាក់ទងទៅនឹងសិទ្ធិលើការបញ្ចាំអចលនវត្ថុរួចមក គឺយើងខ្ញុំអាចធ្វើសេចក្តីសន្និដ្ឋានបានថា ជាគោលការណ៍ ដើម្បីឱ្យកិច្ចសន្យាការដាក់បញ្ចាំអចលនវត្ថុ មានសុពលភាព និងលក្ខណៈគតិយុត្តិ គូភាគីនៃកិច្ចសន្យាត្រូវគោរពលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៅពេលបង្កើត។

សិទ្ធិលើការបញ្ចាំអចលនវត្ថុ កើតឡើងនៅពេលដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ហើយមិនអនុញ្ញាតឱ្យប្រគល់នូវអចលនវត្ថុនោះតាមរយៈលក្ខណៈនៃការកាន់កាប់នោះទេដែលគ្រាន់តែមានការព្រមព្រៀងគ្នាដោយគ្មានការប្រគល់ដោយជាក់ស្តែង។ វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំអចលនវត្ថុ អាចជាអចលនវត្ថុពីកំណើត អាចជាអចលនវត្ថុតាមការកំណត់របស់ច្បាប់។ សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុបញ្ចាំ។

ចំពោះកិច្ចសន្យាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្រោមទម្រង់ជាលិខិតយថាភូត ឬលិខិតឯកជនទើបមានភាពរឹងមាំតាមគន្លងច្បាប់។ ច្បាប់ភូមិបាលតម្រូវឱ្យបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុតាមទម្រង់លិខិតយថាភូតទើបយកជាការបាន និងតតាំងជាមួយតតិយជនបាន។ ពុំមានកិច្ចសន្យាបញ្ចាំអចលនវត្ថុនោះទេ បើគ្មានការផ្ទេរការកាន់កាប់អចលនវត្ថុនោះទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ឬអ្នកតំណាងនៃម្ចាស់សិទ្ធិលើការបញ្ចាំ ព្រោះថាការបញ្ចាំអចលនវត្ថុដោយមិនអាចផ្ទេរការកាន់កាប់ គ្រាន់តែប្រគល់បណ្ណកម្មសិទ្ធិជំនួសអចលនវត្ថុនោះ គេអាចបង្កើតកិច្ចសន្យាហ៊ីប៉ូតែកនោះជំនួសវិញបាន។ ម្យ៉ាងទៀត ដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានលទ្ធភាពតតាំងជាមួយតតិយជនបាន លុះត្រាតែកិច្ចសន្យាបញ្ចាំអចលនវត្ថុនោះធ្វើឡើងដោយលិខិតយថាភូត និងបានចុះបញ្ជីក្នុងសៀវភៅបញ្ជីដីធ្លី។

ក្រមរដ្ឋប្បវេណី មិនអនុញ្ញាតឱ្យគូភាគីព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំឡើងទៅ ប៉ុន្តែកិច្ចសន្យាបញ្ចាំនោះអាចធ្វើបន្តទៀតបានលើអចលនវត្ថុដដែល។ អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ)ឆ្នាំ បានឡើយ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ។ កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអាចធ្វើបន្តទៀតបាន។ ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាចឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ។

ការអនុវត្តកិច្ចសន្យាបញ្ចាំអចលនវត្ថុ នៅក្នុងច្បាប់គេបានកំណត់ថា ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំបាន ហើយមានកាតព្វកិច្ចត្រូវថែ

រក្សាទ្រព្យបញ្ចាំនោះឱ្យបានត្រឹមត្រូវរហូតដល់ពេលបញ្ចប់នៃកិច្ចសន្យា។ ម្ចាស់បំណុលដែលបានកាន់កាប់ទ្រព្យដាក់បញ្ចាំ អាចមានសិទ្ធិអាស្រ័យផលពីទ្រព្យនោះដូចជាផលុបភោគីដែរ លុះត្រាតែមានចែងក្នុងកិច្ចសន្យាដាក់បញ្ចាំ។ ម្ចាស់បំណុលមានកាតព្វកិច្ចថែទាំរក្សាទុកទ្រព្យនោះឱ្យដូចជាទ្រព្យរបស់ខ្លួន។ បើទ្រព្យនោះខូចខាតដោយអំពើ ឬកំហុសណាមួយរបស់ខ្លួន ខ្លួនត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុល។
ទោះបីការដាក់បញ្ចាំអចលនវត្ថុ ធ្វើឱ្យម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើវត្ថុនោះពិតមែន ប៉ុន្តែក្នុងករណីដែលមានវិវាទកើតឡើង ម្ចាស់បំណុលមិនមានសិទ្ធិយកទ្រព្យបញ្ចាំធ្វើជាកម្មសិទ្ធិ ឬលក់ទ្រព្យនោះដើម្បីកាត់បំណុលបញ្ចាំនោះបានទេ។ កិច្ចសន្យាបញ្ចាំអចលនវត្ថុ អនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការឱ្យដាក់លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាព ដោយបរិមា និងបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត។ បើសិនជាក្នុងរយៈពេលនៃកិច្ចសន្យាបញ្ចាំ ម្ចាស់បំណុលដែលទទួលបញ្ចាំទិញអចលនវត្ថុដែលដាក់បញ្ចាំ កិច្ចសន្យាទិញនេះត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ពុំនោះទេនឹងត្រូវចាត់ទុកជាមោឃៈ។

ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី។ ស្ថាប័នអនុវត្តគឺតុលាការអនុវត្ត ឬអាជ្ញាសាលា។ របៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់គូភាគី សញ្ញាណបៃលិខិតអនុវត្ត សេចក្តីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តដោយជំនួស ឬវិធានបង្ខំដោយប្រយោល និងសញ្ញាណនៃទ្រព្យដែលសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ព្រមទាំងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ និងខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ។

សរុបសេចក្តីមក សិទ្ធិលើការបញ្ចាំអចលនវត្ថុ គឺជាគ្រឹះមួយដ៏សំខាន់ក្នុងបរិបទនៃការបញ្ចាំអចលនវត្ថុដោយមិនអាចខ្វះបានឡើយ។ ម្យ៉ាងវិញទៀត ដើម្បីកុំឱ្យមានការយល់ច្រឡំរវាងហ៊ីប៉ូតែក និងការដាក់បញ្ចាំ នៅក្នុងខ្លឹមសារនៃអត្ថបទនេះបានធ្វើការប្រៀបធៀបពីលក្ខណៈខុសគ្នា និងខុសគ្នារវាងការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំ។ ជាក់ស្តែងសព្វថ្ងៃនេះ ប្រជាពលរដ្ឋទូទៅតែងមានការយល់ច្រឡំអំពីការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំ ដោយយល់ថាការដែលខ្លួនបានយកអចលនទ្រព្យរបស់ខ្លួនដាក់ធនាគារគឺជាការបញ្ចាំទៅវិញ ប៉ុន្តែនេះជាការដាក់បហ៊ីប៉ូតែក ព្រោះកូនបំណុលនៅតែមានសិទ្ធិក្នុងការកាន់កាប់ទ្រព្យបញ្ចាំនោះ។ ផ្ទុយទៅវិញការដាក់

បញ្ចាំគឺកូនបំណុលពុំមានសិទ្ធប្រើប្រាស់ទ្រព្យបញ្ចាំនោះទេ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើទ្រព្យបញ្ចាំនោះបាន រហូតដល់រលត់កាតព្វកិច្ចរបស់កូនបំណុល។

# អនុសាសន៍

# អនុសាសន៍

សព្វថ្ងៃនេះការរស់នៅរបស់ប្រជាពលរដ្ឋយើង នៅមានភាពខ្វះចន្លោះច្រើនផ្នែកច្បាប់។ ជាក់ស្តែងពាក់ព័ន្ធនឹងការដាក់បញ្ចាំនេះផ្ទាល់តែម្តង ដែលធ្វើឱ្យអ្នកខ្លះដើម្បីចង់បានប្រាក់ដើម្បីយកមកប្រើប្រាស់ក៏បានសម្រេចចិត្តយកទ្រព្យសម្បត្តិរបស់ខ្លួនទៅដាក់បញ្ចាំ ដោយពុំបានគិតអំពីលទ្ធភាពសងរបស់ខ្លួនទៅម្ចាស់បំណុលវិញឡើយ។ នេះហើយគឺជាហានិភ័យខ្ពស់បំផុត ដែលជាមូលហេតុអាចធ្វើឱ្យម្ចាស់បំណុលមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការរឹបអូសទ្រព្យនោះដើម្បីសងបំណុល។ ក្នុងនាមយើងខ្ញុំគឺជានិស្សិតច្បាប់មួយរូប ដែលទទួលបានការសិក្សាអស់រយៈពេលកន្លងមក សូមធ្វើការចែករំលែកនូវបទពិសោធន៍ទាក់ទងនឹងផ្លូវច្បាប់មួយចំនួនផងដែរ។

ទោះបីយើងត្រូវការប្រាក់ដើម្បីប្រើប្រាស់ក៏ដោយ យើងត្រូវសិក្សាឱ្យបានច្បាស់ថា តើយើងអាចនឹងមានលទ្ធិភាពដើម្បីសងម្ចាស់បំណុលវិញឬទេ។ ប្រសិនបើសិក្សាចំពោះប្រាក់ណូលរបស់ខ្លួនឃើញថា ពុំមានលទ្ធភាពសងវិញទេ នោះពុំគួរខ្ចីប្រាក់ឡើយ។ ប៉ុន្តែក្នុងករណីដែលយើងមិនអាចចៀសបាន ដែលត្រូវតែខ្ចីប្រាក់ដើម្បីប្រើប្រាស់ យើងគួរសិក្សាតាមផ្លូវច្បាប់ដូចជា៖ ១ ការដាក់បញ្ចាំជាចលនវត្ថុ, ២ ការដាក់បញ្ចាំជាអចលនវត្ថុ, និង ៣ ការដាក់បញ្ចាំសិទ្ធិ។ នេះគឺជាលទ្ធិភាពដែលអាចធ្វើឱ្យខ្ចីប្រាក់បាន ប៉ុន្តែរាល់ការដាក់បញ្ចាំ ត្រូវបានចងភ្ជាប់នូវកិច្ចសន្យាដើម្បីចងភ្ជាប់នូវកាតព្វកិច្ចរវាងគូភាគីទាំងសងខាង។ ដូច្នេះហើយភាគីទាំងសងខាងត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយមិនអាចរំលោភច្បាប់បានឡើយ។ ក្នុងករណីមានភាគីណាម្ខាងដែលមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួននោះទេ ម្ចាស់បំណុលមិនមានសិទ្ធិយកទ្រព្យនោះផ្តាច់បានឡើយ ព្រោះច្បាប់បានហាមឃាត់មិនឱ្យធ្វើការបញ្ចាំផ្តាច់នោះទេ។ ហើយជាពិសេសនោះ ម្ចាស់បំណុលទោះបីមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិជាការដាក់បញ្ចាំនោះក៏ដោយ ក៏ពុំមានសិទ្ធិក្នុងការរឹបអូសទ្រព្យណាមួយរបស់កូនបំណុលដើម្បីកាត់បំណុលរបស់ខ្លួននោះឡើយ ព្រោះវាខុសទៅនឹងផ្លូវច្បាប់។ ដើម្បីចង់រឹបអូសទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីកាត់បំណុលរបស់ខ្លួនបានលុះត្រាតែម្ចាស់បំណុលធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីសុំឱ្យតុលាការលក់ទ្បៃទ្បុងទ្រព្យនោះទៅតាមហាងឆេង ដែលកូនបំណុលបានដាក់បញ្ចាំនោះដើម្បីយកមកសងបំណុលរបស់ខ្លួន ហើយប្រាក់ដែលសល់ពីការសងម្ចាស់បំណុលប៉ុន្មានត្រូវប្រគល់ទៅឱ្យកូនបំណុលវិញ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងក្រម

១. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

២. ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

៣. ច្បាប់ភូមិបាលឆ្នាំ២០០១

## ក្រឹត្យច្បាប់

- ក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា នៃសាធារណរដ្ឋមានិតកម្ពុជា

## សៀវភៅ

- សៀវភៅក្រមរដ្ឋប្បវេណីភាគ៥ បោះពុម្ពឆ្នាំ២០១២
- សៀវភៅសេចក្តីពន្យល់ក្រមអំពី ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ

## អ៊ីនធឺណែត

- https://www.construction-property.com/km/similarities-and-differences-between-pledge-and-hypothec/

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ផ្នែកទី៣ ស្តីពី ការបញ្ចាំអចលនវត្ថុ និងផ្នែកទី៤ ស្តីពី ការបញ្ចាំសិទ្ធិ
- ឧបសម្ព័ន្ធទី២ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា គន្ថីទី៦ ស្តីពីការអនុវត្តដោយបង្ខំ, ជំពូកទី១ ផ្នែកទី១ ផ្នែកទី២ ផ្នែកទី៣ ផ្នែកទី៤ និងជំពូកទី២ ផ្នែកទី៤ ការអនុវត្តចំពោះអចលនវត្ថុ, កថាភាគទី១ កថាភាគទី២ កថាភាគទី៣ និងកថាភាគទី៤
- ឧបសម្ព័ន្ធទី៣ ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ
- ឧបសម្ព័ន្ធទី៤ កិច្ចសន្យាខ្ចីប្រាក់ និងដាក់បញ្ចាំ
- ឧបសម្ព័ន្ធទី៥ កិច្ចសន្យាខ្ចីបរិភោគ

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ក្រមរដ្ឋប្បវេណី

Scanned with CamScanner

**មាត្រា ៨៣៣.-** លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ ។

## ផ្នែកទី ៣
## ការបញ្ចាំអចលនវត្ថុ

**មាត្រា ៨៣៤.-** សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ ។

២-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។

៣-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែ ទោះបីជារដូវប្រមូលផលនោះ នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង ។



Scanned with CamScanner

**មាត្រា ៨៣៥.–** បន្ទុកសោហ៊ុយគ្រប់គ្រង

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ។

**មាត្រា ៨៣៦.–** ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។

**មាត្រា ៨៣៧.–** អានុភាពនៃការសន្យាពិសេស

បញ្ញត្តិនៃមាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) មាត្រា ៨៣៥ (បន្ទុកសោហ៊ុយគ្រប់គ្រង) និង មាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨៣៨.–** អំឡុងពេលដែលមានអត្ថិភាព

១-អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។

២-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ ។

**មាត្រា ៨៣៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

## ផ្នែកទី ៤
## ការបញ្ចាំសិទ្ធិ

**មាត្រា ៨៤០.-** កម្មវត្ថុនៃការបញ្ចាំសិទ្ធិ

១-សិទ្ធិលើការបញ្ចាំអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិបាន ។

២-ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤ (ការបញ្ចាំសិទ្ធិ) នេះ បញ្ញត្តិនៃផ្នែកទី ២ (ការបញ្ចាំចលនវត្ថុ) និង ផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៨៤១.-** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មកធ្វើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ សិទ្ធិលើការបញ្ចាំនេះ មិនអាចតតាំងចំពោះកូនបំណុលទី ៣ និងតតិយជនផ្សេងទៀតបានឡើយ លើកលែងតែករណីដែលបានជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជន ក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាក ។

**មាត្រា ៨៤២.-** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបាន ។

២-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុល ត្រឹមតែភាគដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើកំណត់ពេល

ត្រូវសងនៃសិទ្ធិលើបំណុលបានមកដល់ មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនេះ អាចឱ្យកូនបំណុលទី ៣ តម្កល់ប្រាក់សងនេះបាន ។ ក្នុងករណីនេះ សិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ។

៤-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ។

## ជំពូកទី ៥
## ហ៊ីប៉ូតែក

### ផ្នែកទី ១
### អត្ថន័យនៃហ៊ីប៉ូតែក

**មាត្រា ៨៤៣.-** អត្ថន័យនៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដែរ ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-ក្នុងករណីដែលច្បាប់ពិសេសទទួលស្គាល់ការយកទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក បញ្ញត្តិនៃច្បាប់ពិសេសនោះត្រូវយកមកអនុវត្ត ។

### ផ្នែកទី ២
### ការបង្កើតហ៊ីប៉ូតែក

**មាត្រា ៨៤៤.-** ការបង្កើតហ៊ីប៉ូតែក

ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង

ព្រះរាជក្រម

នស/រកម/០៧០៦/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ក្រម
# នីតិវិធីរដ្ឋប្បវេណី

## ផ្នែកទី ៤
## លំនាំនៃការអនុវត្តដោយបង្ខំ

**មាត្រា ៣៤៩.–** របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

១-ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តៈ

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃលិខិតអនុវត្ត ។

គ-សេចក្ដីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។

ឃ-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។

ង-ខ្លឹមសារនៃសេចក្ដីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល ។

៣-ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្ដីសុំ និង ទំហំនៃសេចក្ដីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

**មាត្រា ៣៥០.–** លិខិតអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត ។

២-លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ខាងក្រោមនេះ :

ក-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ ។

ខ-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

គ-ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ ។

ឃ-ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន ។

ង-ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី) នៃក្រមនេះ ។

ច-លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ ។ ប៉ុន្តែ មានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែង-ការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ។

ឆ-សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុ-វត្ត ដែលបានចូលជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៣៥២ (សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស) នៃក្រមនេះ ។

ជ-សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថា-ពរតាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ) នៃក្រមនេះ ។

ឈ-កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនេះ និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ។

**មាត្រា ៣៥១.-** វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ

១-ការអនុវត្តដោយបង្ខំ អាចធ្វើបាន ដោយចង្អុលអ្នកដែលបានកំណត់ខាងក្រោមនេះ ជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ៖

ក-ភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ។

# ផ្នែកទី ៤

# ការអនុវត្តចំពោះអចលនវត្ថុ

## កថាភាគទី ១

## កម្មវត្ថុនៃការអនុវត្តចំពោះអចលនវត្ថុ ស្ថាប័នអនុវត្ត វិធីអនុវត្ត វិធីបែងចែក មធ្យោបាយប្រកាសជាសាធារណៈ និង ការចាត់ចែងការរក្សាការពារ

**មាត្រា ៤១៧.-** កម្មវត្ថុ និងវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

១-នៅផ្នែកទី ៤ នេះ អចលនវត្ថុសំដៅទៅលើដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ អាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និង ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម ។

២-ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ ។

៣-ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និង ឯកសារខាងក្រោមនេះ :

ក-ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

ខ-ចំពោះដីដែលមិនបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤១៨.-** តុលាការអនុវត្ត

ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តុលាការដែលបានកំណត់ខាងក្រោមនេះគឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច :

ក-បើយកដី ឬ អាគារដែលបានចុះបញ្ជី ជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ ។

ខ-បើយកចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ លើអាគារដែលបានចុះបញ្ជី ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ឬ ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួមជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី ។

**មាត្រា ៤១៩.-** ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍

១-នៅពេលចាប់ផ្ដើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត ក្នុងដីកាសម្រេចចាប់ផ្ដើមនេះ ។

២-ដីកាសម្រេចចាប់ផ្ដើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៣-ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៤២០.-** ការផ្តុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាអាទិ៍

១-បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះជាបន្ទាន់ ។

២-បើបានធ្វើការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើការផ្តុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី ។

**មាត្រា ៤២១.-** អានុភាពនៃការរឹបអូស

១-អានុភាពនៃការរឹបអូសអចលនវត្ថុ មានទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និងជាផ្នែកមួយនៃអចលនវត្ថុនោះ ព្រមទាំងវត្ថុចំណុះនិងសិទ្ធិចំណុះនៃអចលនវត្ថុនោះ ។

២-អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានបញ្ជូន ទៅកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្តើមនោះ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៣-ការរឹបអូសពុំត្រូវរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុ តាមវិធីប្រើធម្មតាឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ ត្រូវបានរឹបអូស ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) និង ករណីដែលការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤២៩ (ការចាត់ចែងការរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៤២២.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ

១-ក្នុងករណីដែលអានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ

លើកលែងតែករណីដែលបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រួតគ្នា ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) នៃក្រមនេះ ។

២-នៅពេលដែលពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកត្រូវបានកំណត់ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្តើមត្រូវបានចេញ និង អំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ហើយត្រូវដាស់តឿនឱ្យជនដែលបានកំណត់ខាងក្រោមនេះ រាយការណ៍ទៅតុលាការអនុវត្ត អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុល និង មូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក :

ក-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូងចំពោះអចលនវត្ថុនោះ ។

ខ-ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូង ចំពោះអចលនវត្ថុនោះ ។

គ-ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬ អាករសាធារណៈផ្សេងទៀត ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ តុលាការអនុវត្តត្រូវដាស់តឿនចំពោះជនដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី ២ អំពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-ការរាយការណ៍អំពីអត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

ខ-កិច្ចដែលត្រូវដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ក្នុងករណីដែលមានឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ ។

៤-បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកបាន ។

៥-បើបានផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយ

យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការផ្លាស់ប្តូរនោះ ។

**មាត្រា ៤២៣.-** កាតព្វកិច្ចរបស់ជនដែលត្រូវបានផាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល

១-ជនដែលបានកំណត់នៅក្នុងចំណុច ក ខ ឬ គ នៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ) នៃក្រមនេះ ដែលត្រូវបានផាស់តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ ទី ៣ នៃមាត្រា ៤២២ នោះ ត្រូវរាយការណ៍អំពីចំណុចដែលបានកំណត់នៅក្នុងសេចក្តីផាស់តឿននោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

២-បើមានការផ្លាស់ប្តូរចំនួនប្រាក់ដើមនៃសិទ្ធិលើបំណុល ដែលទាក់ទងនឹងសេចក្តីរាយការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ជនដែលបានធ្វើសេចក្តីរាយ-ការណ៍នោះ ត្រូវរាយការណ៍អំពីការផ្លាស់ប្តូរនោះ ។

៣-បើជនដែលត្រូវរាយការណ៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ពុំបានធ្វើសេចក្តីរាយការណ៍នោះ ឬ បានធ្វើសេចក្តីរាយការណ៍មិនពិត ដោយចេតនា ឬ ដោយមានកំហុស ជននោះត្រូវទទួលខុសត្រូវសងការខូចខាតដែលបានកើតឡើងដោយសារហេតុនោះ ។

**មាត្រា ៤២៤.-** ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា

១-បើមានពាក្យសុំឱ្យអនុវត្តដោយបង្ខំថ្មីទៀត ចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានសម្រេចរួចហើយ ហើយបើទទួលស្គាល់ពាក្យសុំនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំថ្មីទៀត ។ ក្នុងករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ។

២-បើពាក្យសុំឱ្យលក់ដោយបង្ខំដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានដក ឬ នីតិវិធីនៃការលក់ដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមមុន ត្រូវបានលុបចោល តុលាការអនុវត្តត្រូវបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយ

បង្ខិក្រោយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខិក្រោយនោះ ផ្អែកលើពាក្យសុំដែលបានដាក់ក្រោយពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី ។ ក្នុងករណីនេះ តុលាការអនុវត្តមិនចាំបាច់ដាស់តឿន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤២២ (ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ) ចំពោះជនដែលបានធ្វើសេចក្ដីរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៣ (ករណី-យកិច្ចរបស់ជនដែលត្រូវបានដាស់តឿនក្នុងការរាយការណ៍អំពីសិទ្ធិលើបំណុល) នៃក្រមនេះឡើយ ។

៤-បើនីតិវិធីនៃការលក់ដោយបង្ខិដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមមុនត្រូវបានផ្អាក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមក្រោយ ។ ក្នុងករណីនេះ តុលាការអនុវត្តអាចចេញដីកាសម្រេចបន្តនីតិវិធី ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ក្រោយដែលផ្អែកលើពាក្យសុំឱ្យអនុវត្តដោយបង្ខិដែលបានធ្វើឡើងនៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកតាមពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការផ្លាស់ប្ដូរនឹងកើតឡើងចំពោះចំណុចដែលបានកំណត់ពីចំណុចទី ១ ដល់ចំណុចទី ៣ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ បើការលក់ដោយបង្ខិដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុនត្រូវបានលុបចោល ។

៥-បើមានដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ តុលា-ការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៦-ចំពោះដីកាសម្រេចលើកចោលពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៤២៥.-** ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ

បញ្ញត្តិចាប់ពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៣ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានចេញរួចហើយ ។

**មាត្រា ៤២៦.-** ការទាមទារឱ្យចែកចំណែក

១-ជនដែលបានកំណត់ខាងក្រោមនេះ អាចទាមទារឱ្យចែកចំណែកបាន :

ក-ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអាចអនុវត្តដោយបង្ខំបាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស ដែលនឹងបន្តអត្ថិភាព ក្រោយការលក់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ ។

ខ-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសបណ្តោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ។

គ-ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិទូទៅ ។

២-ការទាមទារឱ្យចែកចំណែកត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយសរសេរនូវមូលហេតុ និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដោយរួមបញ្ចូលទាំងការប្រាក់ និង សិទ្ធិលើបំណុលបន្ទាប់បន្សំឯទៀត ។

៣-បើមានការទាមទារឱ្យចែកចំណែក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ។

៤-ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក អាចប្តឹងជំទាស់បាន ។

**មាត្រា ៤២៧.-** ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ជាអាទិ៍នៃអចលនវត្ថុ

បើមានភាពច្បាស់លាស់អំពីស្ថានភាពដែលបានបាត់បង់អចលនវត្ថុ ឬ ស្ថានភាពផ្សេងដែលរារាំងការផ្ទេរអចលនវត្ថុដោយការលក់ តុលាការអនុវត្តត្រូវលុបចោលនីតិវិធី

នៃការលក់ដោយបង្ខំ ។

**មាត្រា ៤២៨.–** ការផ្អាកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស

១-បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើង ក្រឡាបញ្ជីត្រូវផ្អាកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះ ។

២-សោហ៊ុយចាំបាច់សម្រាប់ការផ្អាកផ្តាក់ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ ។

**មាត្រា ៤២៩.–** ការចាត់ចែងការរក្សាការពារ

១-ប្រសិនបើកូនបំណុល ឬ អ្នកកាន់កាប់អចលនវត្ថុបានប្រព្រឹត្តអំពើដែលធ្វើឱ្យតម្លៃអចលនវត្ថុចុះថយគួរឱ្យកត់សំគាល់ ឬ ធ្វើឱ្យមានការលំបាកដល់ការលក់ ឬ ការប្រគល់អចលនវត្ថុ ឬ បើមានការបារម្ភថា អ្នកនោះនឹងប្រព្រឹត្តអំពើខាងលើនេះ តុលាការអនុវត្តអាចហាមឃាត់ជនដែលបានប្រព្រឹត្តអំពើទាំងនេះ ឬ ជនដែលត្រូវគេមានការបារម្ភថា នឹងប្រព្រឹត្តអំពើទាំងនេះ មិនឱ្យប្រព្រឹត្តអំពើនោះ ឬ បង្គាប់ឱ្យជននោះធ្វើសកម្មភាពណាមួយជាកំណត់ ឬ បង្គាប់ឱ្យជននោះលះបង់ការកាន់កាប់អចលនវត្ថុហើយឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុនោះបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ដោយឱ្យដាក់ ឬ មិនឱ្យដាក់ប្រាតិភោគ ។ ប៉ុន្តែ មានតែករណីដែលអ្នកកាន់កាប់អចលនវត្ថុ មិនអាចយកមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ តតាំងនឹងអ្នកទិញទេ ទើបអាចបង្គាប់ឱ្យជននោះប្រគល់អចលនវត្ថុឱ្យអាជ្ញាសាលា ដើម្បីឱ្យថែរក្សាគ្រប់គ្រងបាន ។

២-ក្នុងករណីចេញដីកាសម្រេចដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ចំពោះអ្នកកាន់កាប់ផ្សេងពីកូនបំណុល តុលាការអនុវត្តត្រូវសួរជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពបន្ទាន់ចាំបាច់ត្រូវចេញដីកាសម្រេចនោះ ។

៣-បើស្ថានភាពមានការប្រែប្រួល តុលាការអនុវត្តអាចលុបចោល ឬ កែប្រែដីកា

សម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំបាន ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជានៅមុនពេលដែលត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

៦-សោហ៊ុយចាំបាច់សម្រាប់ពាក្យសុំ ឬ ការអនុវត្តដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុនោះ ។

## កថាភាគទី ២

## ល័ក្ខខ័ណ្ឌនៃការលក់

**មាត្រា ៤៣០.-** ការវាយតម្លៃ

១-តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត ។

២-ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។

៣-នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ។

៤-បើមានភាពចាំបាច់ អាជ្ញាសាលាដែលអ្នកវាយតម្លៃបានសុំជាជំនួយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលាជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅកាន់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

៥-អ្នកវាយតម្លៃត្រូវដាក់ជូនតុលាការអនុវត្តជាលាយលក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និង ការវាយតម្លៃអចលនវត្ថុនោះ ។

**មាត្រា ៤៣១.-** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់

១-ក្នុងចំណោមសិទ្ធិប្រាតិភោគប្រយុក្ស សិទ្ធិប្រយុក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួលដែលមានលើអចលនវត្ថុ ចំពោះសិទ្ធិដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ ។

២-សិទ្ធិលើអចលនវត្ថុ ក្រៅពីសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរលត់ដោយសារការលក់ ។

៣-ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដែលពាក់ព័ន្ធនឹងអចលន-វត្ថុ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលពុំអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្តោះអាសន្ន ត្រូវបាត់បង់អានុភាព ដោយសារការលក់ ។

៤-មុនពេលដែលតម្លៃលក់អប្បបរមាត្រូវបានកំណត់ បើបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍បានរាយការណ៍ថា ការព្រមព្រៀងដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវបានធ្វើឡើង ការប្រែប្រួលនៃសិទ្ធិលើអចលនវត្ថុ ដោយការលក់ ត្រូវអាស្រ័យតាមការព្រមព្រៀងនោះ ។

**មាត្រា ៤៣២.-** ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍

១-តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ ។

២-បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចផ្លាស់ប្តូរតម្លៃលក់អប្បបរមាបាន ។

**មាត្រា ៤៣៣.-** ការលក់សរុប

បើយល់ឃើញថាជាការសមរម្យក្នុងការឱ្យអ្នកទិញណាមួយ ទិញសរុបតែម្តងនូវអចល-នវត្ថុ ជាមួយនឹងអចលនវត្ថុផ្សេងទៀត ដោយយោងតាមទំនាក់ទំនងគ្នាក្នុងការប្រើប្រាស់ ទោះបីជាអចលនវត្ថុនីមួយៗនោះមានម្ចាស់បំណុលនៃការអនុវត្តផ្សេងគ្នា ឬ កូនបំណុល

នៃការអនុវត្តផ្សេងគ្នាក៏ដោយ ក៏តុលាការអនុវត្តអាចកំណត់ការលក់អចលនវត្ថុទាំងនោះសរុបតែម្តងបាន ។ ប៉ុន្តែ ក្នុងករណីដែលមានលទ្ធភាពអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ដោយការលក់អចលនវត្ថុណាមួយក្នុងតម្លៃលក់អប្បបរមា ក្នុងចំណោមអចលនវត្ថុច្រើន ដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានសម្រេច តាមពាក្យសុំតែមួយនោះ តុលាការអនុវត្តអាចកំណត់ការលក់សរុបតែម្តងបាន លុះត្រាតែមានការយល់ព្រមពីកូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤៣៤.–** ឯកសារលំអិតអំពីវត្ថុ

១-តុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីវត្ថុ ហើយត្រូវទុកឯកសារចម្លងនៃឯកសារលំអិតអំពីវត្ថុនោះ នៅតុលាការអនុវត្ត ជាមួយគ្នានឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ ដើម្បីផ្តល់ឱ្យសាធារណជនមើល ។ ឯកសារលំអិតអំពីវត្ថុ ត្រូវសរសេរចំណុចដូចខាងក្រោមនេះ :

ក-សញ្ញាណនៃអចលនវត្ថុ ។

ខ-សិទ្ធិលើអចលនវត្ថុដែលនឹងបន្តអត្ថិភាពក្រោយការលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនេះ និង ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ដែលមិនបាត់បង់អានុភាពដោយការលក់ ។

២-បើយល់ឃើញថាចាំបាច់ ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តអាចបង្គាប់ឱ្យអាជ្ញាសាលាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ដូចជាសណ្ឋាននៃអចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ របនាសម្ព័ន្ធនៃអាគារបើមានអាគារ ឬ បើកម្មវត្ថុនៃការអនុវត្តគឺជាអាគារ ជាអាទិ៍ ហើយរាយការណ៍លទ្ធផលនៃការស្រាវជ្រាវនោះជាលាយល័ក្ខណ៍អក្សរ ។

៣-នៅពេលធ្វើការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ តាមការបង្គាប់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាជ្ញាសាលាមានសិទ្ធិអំណាចដូចនឹងសិទ្ធិអំណាចរបស់អ្នកវាយតម្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៤៣០ (ការវាយតម្លៃ) នៃក្រមនេះ ។ បើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់

ដើម្បីបើកទ្វារដែលបិទបាន ។

**មាត្រា ៤៣៥.-** វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់

១-ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-សំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ក្នុងករណីដែលគ្មានសំណើទិញក្នុងតម្លៃដែលឡើងដល់តម្លៃស្នើសុំនោះ ។ ប៉ុន្តែ សំណើនោះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយតម្លៃស្នើសុំនោះ ត្រូវលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ។

ខ-ការដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

## កថាភាគទី ៣
## វិធីលក់

**មាត្រា ៤៣៦.-** វិធីលក់ជាអាទិ៍

១-ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

២-តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៣-ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់

តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ ។

៤-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។

៥-បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្ដាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៣៧.–** ការធានាលើសំណើទិញ

១-ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានា លើសពីចំនួននេះបាន ។

២-ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាការអនុវត្តត្រូវសងភ្លាមនូវប្រាក់ធានាដែលបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦ (វិធីលក់ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៤៣៨.–** ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៣៩.–** ការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ជាអាទិ៍

១-បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញ ក្នុងតម្លៃអតិបរមា និង បានប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកទិញ និង ថ្ងៃលក់ឡាយឡុងនោះ ។

២-បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា

មានច្រើននាក់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត ។ ក្នុងករណីនេះ អ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ ។

៣-បើអ្នកដេញថ្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនដេញថ្លៃម្តងទៀតទេ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដេញថ្លៃដោយស្រោមសំបុត្រដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ នៅក្នុងការលក់ឡាយឡុងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នោះ ។

៤-បើបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ដែលសរសេរនូវចំណុចដូចខាងក្រោម ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាម:

ក-សញ្ញាណនៃអចលនវត្ថុ ។

ខ-កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

គ-សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង អ្នកតំណាង ។

ឃ-តម្លៃទិញរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ង-ហេតុការណ៍នោះ និង ស្ថានភាព បើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ច-មូលហេតុ និង វិធានការដែលបានចាត់ធ្វើ បើបានចាត់វិធានការដែលបានកំណត់នៅក្នុងមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ។

៥-អាជ្ញាសាលាត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

**មាត្រា ៤៤០.-** កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

១-តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។

២-នៅពេលដែលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលា-

ការអនុវត្តត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះ ទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ៤៤១.-** ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់អចលនវត្ថុ អាចថ្លែងយោបល់អំពីហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ដែលបណ្តាលឱ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន នៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់បាន ។

**មាត្រា ៤៤២.-** ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ។

២-តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ បើទទួលស្គាល់ថា មានហេតុណាមួយដូចកំណត់ក្នុងចំណុចខាងក្រោមនេះ :

ក-មិនត្រូវចាប់ផ្តើម ឬ បន្តនីតិវិធីនៃការលក់ដោយបង្ខំ ។

ខ-អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬ សមត្ថភាពដើម្បីទិញអចលនវត្ថុ ឬអ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ ។

គ-មានសេចក្តីស្នើសុំកុំឱ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៤៥ (ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត) នៃក្រមនេះ ។

ឃ-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ។

ង-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់ ។

**មាត្រា ៤៤៣.-** វិធានការក្នុងករណីលក់ហួសកម្រិត

១-ក្នុងករណីដែលបានលក់អចលនវត្ថុច្រើន បើតម្លៃស្នើសុំទិញនៃអចលនវត្ថុណាមួយ ឬ ច្រើន ក្នុងចំណោមអចលនវត្ថុទាំងអស់នោះ ត្រូវបានប៉ាន់ប្រមាណឃើញថា អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់

បានតុលាការអនុវត្តត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឱ្យលក់អចលនវត្ថុផ្សេងទៀត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើមានអចលនវត្ថុច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃអចលនវត្ថុនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ឬ បើសមាយោគនៃអចលនវត្ថុមានច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃសមាយោគនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន តុលាការអនុវត្តត្រូវសួរយោបល់របស់កូនបំណុលនៃការអនុវត្តជាមុន អំពីអចលនវត្ថុដែលត្រូវអនុញ្ញាតឱ្យលក់ ។

៣-អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានៃអចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានបម្រុងទុក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលសំណើទិញនោះ ដោយជូនដំណឹងទៅតុលាការអនុវត្តបាន ។

៤-បើថ្លៃលក់ត្រូវបានបង់ចំពោះអចលនវត្ថុដែលមានដីកាសម្រេចអនុញ្ញាតឱ្យលក់ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងអចលន-វត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៤៤.–** បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចប្តឹងជំទាស់បាន លុះត្រាតែក្នុងករណីដែលដីកាសម្រេចនោះបណ្តាលឱ្យមានខូចខាតដល់សិទ្ធិរបស់ខ្លួន ។

២-បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវយកហេតុដូចបានកំណត់ក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ នៃមាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ឬ កំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ មកធ្វើជាមូលហេតុ ។

៣-បើទទួលស្គាល់ថាចាំបាច់ តុលាការនៃបណ្តឹងជំទាស់ អាចកំណត់ភាគីម្ខាងទៀតនៃម្ចាស់បណ្តឹងជំទាស់បាន ។

៤-ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នេះ ពុំមានអានុភាពឡើយ បើមិន

ទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៤៥.-** ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត

១-ក្នុងករណីដែលអចលនវត្ថុបានទទួលការខូចខាតធ្ងន់ធ្ងរ នៅក្រោយពេលធ្វើសំណើទិញដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញអាចស្នើសុំទៅតុលាការអនុវត្តកុំឱ្យអនុញ្ញាតការលក់ ប្រសិនបើនៅមុនពេលចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ អាចដាក់ពាក្យសុំទៅតុលាការអនុវត្តឱ្យលុបចោលដីកាសម្រេចនោះ នៅមុនពេលបង់ប្រាក់បាន ប្រសិនបើនៅក្រោយពេលចេញដីកាសម្រេចអនុញ្ញាតការលក់ហើយ ។

២-ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៣-ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៤៦.-** ការដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលមានសំណើទិញ

ដើម្បីដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលដែលមានសំណើទិញហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការយល់ព្រមពីសំណាក់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ។

## កថាភាគទី ៤

## អានុភាពនៃការលក់

**មាត្រា ៤៤៧.-** ការបង់ថ្លៃលក់

១-បើដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់ ។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ (មួយ) ខែចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរ ។

២-ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

៣-បើអ្នកទិញគឺជាម្ចាស់បំណុលដែលត្រូវទទួលការបែកចំណែកពីប្រាក់លក់ អ្នកទិញនោះអាចបង់ថ្លៃលក់ ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការបែកចំណែកនៅកាលបរិច្ឆេទនៃការបែកចំណែកបាន ដោយស្នើសុំទៅតុលាការអនុវត្ត នៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ។ ក្នុងករណីនេះ បើមានសេចក្តីថ្លែងតវ៉ាអំពីចំនួនប្រាក់នៃការបែកចំណែកដែលអ្នកទិញត្រូវទទួល អ្នកទិញត្រូវបង់ចំនួនប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះជាបន្ទាន់ ។

៤-អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ ។

**មាត្រា ៤៤៨.–** ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់

១-ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និង លុបការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ :

ក-ការចុះបញ្ជី អំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

ខ-ការលុបការចុះបញ្ជី អំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

គ-ការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្នដែលបានបាត់បង់អានុភាពដោយការលក់ ។

ឃ-ការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ។

២-ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ជាមួយនឹងលិខិតផ្ទុកផ្តាក់នោះ ។

៣-សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់អ្នកទិញ ។

**មាត្រា ៤៤៩.–** ការទទួលខុសត្រូវរបស់អ្នកទិញ

១-ចំពោះសិទ្ធិប្រាតិភោគដែលនឹងបន្តអត្ថិភាពក្រោយការលក់ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់

ក្រោយការលក់) នៃក្រមនេះ បើកូនបំណុលនៃការអនុវត្ត ជាកូនបំណុលនៃសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគទាំងនេះ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសង នូវសិទ្ធិលើបំណុលនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសិទ្ធិប្រាតិភោគ ដែលនឹងបន្តអត្ថិភាពក្រោយការលក់ ជាហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អ្នកទិញត្រូវ ទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានា បំណុលអណ្ដែតនោះ ក្នុងកម្រិតនៃចំនួនអតិបរមា ។

**មាត្រា ៤៥០.–** ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ

១-តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នក កាន់កាប់អចលនវត្ថុ ប្រគល់អចលនវត្ថុនោះទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែល បានបង់ថ្លៃលក់ហើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវ បានទទួលស្គាល់ថា កាន់កាប់អចលនវត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយ នឹងអ្នកទិញ ដោយយោងទៅតាមសំណុំរឿងនៃការអនុវត្តដោយបង្ខំ ។

២-បើហួសអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ ហើយអ្នកទិញនោះ ពុំអាចដាក់ពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ។

៣-ក្នុងករណីដែលបានចេញដីកាសម្រេចចំពោះអ្នកកាន់កាប់ ក្រៅពីកូនបំណុលនៃ ការអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរជននោះ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ អាចប្ដឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុ- ភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៥១.–** អានុភាពនៃការមិនបង់ថ្លៃលក់

១-បើអ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ នឹងបាត់បង់ អានុភាព ។ ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឱ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជា

ការធានាលើសំណើទិញបានទេ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្ត ត្រូវលក់ដោយបង្ហិសាជាថ្មី ។

៣-ក្នុងការលក់ដោយបង្ហិតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អ្នកទិញដែល បានកំណត់នៅក្នុងកថាខណ្ឌទី ១ ពុំអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៥២.–** ថ្លៃលក់

១-ប្រាក់ដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ជាថ្លៃលក់សម្រាប់ការចែកចំណែក :

ក-ថ្លៃលក់អចលនវត្ថុ ។

ខ-ទឹកប្រាក់ដែលអ្នកទិញពុំអាចទាមទារឱ្យសងមកវិញបាន តាមបញ្ញត្តិនៃវាក្យ-ខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៤៥១ (អានុភាពនៃការមិនបង់ថ្លៃលក់) នៃក្រមនេះ ។

២-ក្នុងករណីដែលអចលនវត្ថុត្រូវបានលក់ឱ្យស្រេចតែម្តង ដោយយោងតាមបញ្ញត្តិ នៃមាត្រា ៤៣៣ (ការលក់សរុប) នៃក្រមនេះ បើចាំបាច់ត្រូវកំណត់ចំនួនថ្លៃលក់នៃអចល-នវត្ថុនីមួយៗ ចំនួននោះចាត់ជាចំនួនដែលចែកចំនួនសរុបនៃថ្លៃលក់ តាមសមាមាត្រនៃតម្លៃ លក់អប្បបរមានៃអចលនវត្ថុនីមួយៗ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះ បន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្តចំពោះអចលនវត្ថុនីមួយៗ ។

**មាត្រា ៤៥៣.–** វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក

ម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកថ្លៃលក់ គឺជាបុគ្គលដែលកំណត់ដូច ខាងក្រោមនេះ :

ក-ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ហិ ឬ ការលក់ដោយបង្ហិ ដែលជាការអនុវត្តឯកសិទ្ធិទូទៅ រហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យ ចែកចំណែក ។

ខ-ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក រហូតដល់ពេលកំណត់ចុង ក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

គ-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មុនការចុះ បញ្ជីអំពីការរឹបអូសដែលជាមូលដ្ឋាននៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ហិជាដំបូង ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ម្ចាស់បំណុលនៃការអនុវត្ត : ឈ្មោះ.............................ភេទ....... អាយុ......ឆ្នាំ សញ្ជាតិ.......
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .......... ចុះថ្ងៃទី.......
ខែ....... ឆ្នាំ....... មានអាសយដ្ឋានផ្ទះលេខ .......... ផ្លូវលេខ..........
ភូមិ.......... សង្កាត់.......... ខណ្ឌ.......... រាជធានីភ្នំពេញ។

កូនបំណុលនៃការអនុវត្ត : ឈ្មោះ.............................ភេទ....... អាយុ......ឆ្នាំ សញ្ជាតិ.......
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .......... ចុះថ្ងៃទី.......
ខែ....... ឆ្នាំ....... មានអាសយដ្ឋានផ្ទះលេខ .......... ផ្លូវលេខ..........
ភូមិ.......... សង្កាត់.......... ខណ្ឌ.......... រាជធានីភ្នំពេញ។

## សូមគោរពជូន
## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ** : សំណើសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដោយផ្អែកតាមសាលក្រមរដ្ឋប្បវេណីស្ថាពរ លេខ.... ចុះថ្ងៃទី........ ខែ............ ឆ្នាំ........របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** : -មាត្រា៤១៧ មាត្រា៣៤៩ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី
-សាលក្រមរដ្ឋប្បវេណីលេខ.......ចុះថ្ងៃទី...ខែ....ឆ្នាំ..របស់សាលាដំបូងរាជធានីភ្នំពេញ
-រូបមន្តអនុវត្តលេខ.......ចុះថ្ងៃទី...ខែ....ឆ្នាំ..របស់សាលាដំបូងរាជធានីភ្នំពេញ
-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ.......ចុះថ្ងៃទី...ខែ....ឆ្នាំ..

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពនិងជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបនូវសញ្ញាណនៃលិខិតអនុវត្ត សេចក្តីស្នើសុំឲ្យអនុវត្ត និងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត ដូចខាងក្រោម៖

### ១.- សញ្ញាណនៃលិខិតអនុវត្ត

ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត គឺ សាលក្រមរដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី.......... ខែ........ ឆ្នាំ........... របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចបញ្ជាប់ ៖

១. .............................................................
២. .............................................................

៣.........................................................................

សាលក្រមនេះបានចូលជាស្ថាពរនៅថ្ងៃទី.......... ខែ.......... ឆ្នាំ២០១..... (ដូចមានបញ្ជាក់នៅក្នុងលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខ............ ចុះថ្ងៃទី........ខែ........ឆ្នាំ.......... ចេញដោយលោក ............ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ) ហើយមានអានុភាពអនុវត្តដោយបង្ខំ ដោយមានភ្ជាប់ជាមួយនូវរូបមន្តអនុវត្តលេខ .......... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ២០១... ដែលចេញដោយលោក ....................................... ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។

## ២.- សេចក្តីស្នើសុំឲ្យអនុវត្ត

សំណើសុំឲ្យស្ថាប័នអនុវត្ត (តុលាការអនុវត្ត) អនុវត្តតាមវិធានបង្ខំដោយផ្ទាល់ ដោយសុំឲ្យលក់ដោយបង្ខំនូវអចលនវត្ថុ (ដូចមានបញ្ជាក់នៅក្នុងចំណុចទី៣នៃពាក្យសុំនេះ) ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ...................... ដើម្បីទទួលបានការសងតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី......... ខែ....... ឆ្នាំ.......... របស់សាលាដំបូងរាជធានីភ្នំពេញ។

## ៣.- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តបង្ខំ គឺជាអចលនវត្ថុ ដែលមានអត្តសញ្ញាណដូចខាងក្រោម៖

- ទំហំ ៖ ...........................................................................................
- ក្បាលដីលេខ ៖ ...........................................................................................
- ទីតាំងស្ថិតនៅ ៖ ផ្ទះលេខ........... ផ្លូវលេខ.......... ភូមិ.............. សង្កាត់.......... ខណ្ឌ........................... រាជធានីភ្នំពេញ
- វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ........... ចុះថ្ងៃទី.........ខែ............ ឆ្នាំ............
- កម្មសិទ្ធិករ ៖ គឺជាកូនបំណុលនៃការអនុវត្តឈ្មោះ............................

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ.......... ឆ្នាំ............

**ម្ចាស់បំណុលនៃការអនុវត្ត**

**ជូនភ្ជាប់មកជាមួយនូវ៖**

| | |
|---|---|
| -សាលក្រមរដ្ឋប្បវេណី(ច្បាប់ដើម) | ចំនួន ០១ ច្បាប់ |
| -រូបមន្តអនុវត្ត (ច្បាប់ដើម) | ចំនួន ០១ ច្បាប់ |
| -លិខិតបញ្ជាក់ការចូលជាស្ថាពរ(ច្បាប់ដើម) | ចំនួន ០១ ច្បាប់ |
| -វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ(ចម្លង) | ចំនួន ០១ ច្បាប់ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យាខ្ចីប្រាក់_ដាក់បញ្ចាំ

រវាងខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី.........ខែ..........ឆ្នាំ......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី "ក" ម្ចាស់ប្រាក់** ។

**និង**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ...................ខេត្ត/ក្រុង....................... ហៅកាត់ថា **ភាគី "ខ" ជាអ្នកខ្ចីប្រាក់** ។

***ភាគី "ក" និងភាគី "ខ" បានព្រមព្រៀង តាមប្រការដូចខាងក្រោម:***

**ប្រការ១:** ភាគី "ក" យល់ព្រមឱ្យភាគី "ខ" ខ្ចីប្រាក់ចំនួន......................ដុល្លារ (..................................................)

ភាគី "ខ" បានទទួលចំនួនទឹកប្រាក់នេះ នៅពេលចុះកិច្ចសន្យាចំពោះមុខសាក្សី និងមេធាវី ។

**ប្រការ២:** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យភាគី "ក" ហើយភាគី "ក" យល់ព្រមទទួលការប្រាក់ពី ភាគី "ខ" ក្នុងអត្រាព្រមព្រៀង.............ភាគរយ ក្នុង១ខែ ស្មើនឹង...................(.................................................) នៃប្រាក់ដែលបានខ្ចី ។ រយៈពេល..................................នៃការខ្ចីប្រាក់ គិតចាប់ពីថ្ងៃទី...........ខែ............ ឆ្នាំ.......... រហូតដល់ថ្ងៃទី..........ខែ..........ឆ្នាំ........... ។

**ប្រការ៣:** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យ ភាគី "ក" នៅថ្ងៃទី............ដើមខែនិមួយៗ ។ ភាគី "ក" យល់ព្រមឱ្យភាគី "ខ" បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណានោះ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី "ខ" មានបំណងចង់ចេញសងរួមទាំងប្រាក់ដើមនិងការប្រាក់ផង ។ ក្នុងករណីភាគី "ខ" ពុំបានបង់ការក្នុងរយៈពេល<u>០៣ខែជាប់ៗគ្នានោះ</u> ភាគី "ខ" យល់ព្រមឱ្យភាគី "ក" ប្រើសិទ្ធិរបស់ខ្លួនក្នុងការបញ្ឈប់ ឬបញ្ចប់កិច្ចសន្យានេះបានដោយឯកតោភាគី ។

ភាគី "ខ" បានយល់ព្រមថា ករណីបង់ការប្រាក់យឺតយ៉ាវរហូតដល់ ០៣ខែ អនុញ្ញាតឱ្យភាគី "ខ" រឹបអូសយកផ្ទះ និងដីដែលបានដាក់បញ្ចាំឱ្យភាគី "ខ" រួចចុះចេញពីផ្ទះ និងដី ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។

**ប្រការ៤:** យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការបំពេញកាតព្វកិច្ចភាគី "ខ" បានដាក់អចលនទ្រព្យធានាមានដូចជា:

| ល.រ | រាយមុខទ្រព្យសម្បត្តិដាក់បញ្ចាំ | ចំនួនច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព:..........................................<br>ចុះថ្ងៃទី.......ខែ.........ឆ្នាំ.........( ក្រុម/ភូមិ...........ឃុំ/សង្កាត់.............)<br>ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង.................................. ។ | | |
| ២ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព:..........................................<br>ចុះថ្ងៃទី.......ខែ.........ឆ្នាំ.........( ក្រុម/ភូមិ...........ឃុំ/សង្កាត់.............)<br>ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង.................................. ។ | | |
| ៣ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព:..........................................<br>ចុះថ្ងៃទី.......ខែ.........ឆ្នាំ.........( ក្រុម/ភូមិ...........ឃុំ/សង្កាត់.............)<br>ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង.................................. ។ | | |

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ច្បាប់ សម្រាប់ភាគី "ក" និងភាគី "ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ................ ថ្ងៃទី.........ខែ...........ឆ្នាំ............

| | | | |
|---|---|---|---|
| **ភាគី "ខ"** | **សាក្សីភាគី "ខ"** | **សាក្សីភាគី "ក"** | **ភាគី "ក"** |
| ឈ្មោះ........................ | ឈ្មោះ.......................... | ឈ្មោះ.......................... | ឈ្មោះ.......................... |

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**មេធាវី**

កិច្ចសន្យាខ្ចីបរិភោគ

អ្នកកាក់តែងលិខិត........................

លេខ:.....................................

ក្រដាសពុម្ពលេខ:..............

មិនុកឯកសារ

## កិច្ចសន្យាខ្ចីបរិភោគ

**១. ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា**

១. កូនបំណុលឈ្មោះ ........................ភេទ............ថ្ងៃខែឆ្នាំកំណើត:...............សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:............................ចុះថ្ងៃទី...............មានអាស័យដ្ឋានផ្ទះលេខ:... ផ្លូវលេខ:..........ភូមិ............សង្កាត់....................ខណ្ឌ..............រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

អ្នកធានាដោយវត្ថុឈ្មោះ............................ភេទ.......ថ្ងៃខែឆ្នាំកំណើត:............... សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:............................ចុះថ្ងៃទី.........................និង ឈ្មោះ............................ភេទ.......ថ្ងៃខែឆ្នាំកំណើត:......................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:.........................ចុះថ្ងៃទី.........................មានលំនៅផ្ទះលេខ:......... ផ្លូវលេខ:.........ភូមិ...........សង្កាត់....................ខណ្ឌ......................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ក") ។

២. ម្ចាស់បំណុលឈ្មោះ..........................ភេទ.......ថ្ងៃខែឆ្នាំកំណើត:...............សញ្ជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ:......................ចុះថ្ងៃទី...............មានលំនៅផ្ទះលេខ:.......ភូមិ... សង្កាត់...............ខណ្ឌ..................រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (តទៅហៅថាភាគី "ខ") ។

**២. សិទ្ធលើបំណុលដែលត្រូវធានាដោយសិទ្ធិលើការបញ្ចាំ**

កូនបំណុលឈ្មោះ..........................ភេទ.........ថ្ងៃខែឆ្នាំកំណើត:.................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:.......................ចុះថ្ងៃទី......................និងលោកស្រី.............. ភេទ.........ថ្ងៃខែឆ្នាំកំណើត:.......................សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:............ ចុះថ្ងៃទី.........................មានលំនៅផ្ទះលេខ:........ផ្លូវលេខ:.......សង្កាត់...........ខណ្ឌ........... រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

(១). ចំនួនប្រាក់ដើម........................................

(២). រយៈពេល........................................

(៣). ការប្រាក់........................................

(៤). ប្រាក់ធានាសង........................................

(៥). ការសន្យាពិសេសកិច្ចសន្យានេះធ្វើឡើង សម្រាប់រយៈពេល..........ឆ្នាំ ប៉ុន្តែកិច្ចសន្យានេះអាចបញ្ចប់ ឬរំលាយមុនរយៈពេលនេះបាន ក្នុងករណីភាគីណាមួយបំពានចំណុចណាមួយ នៃបញ្ញត្តិស្តីពីការបំពានលើកាតព្វកិច្ចដូចមានចែងនៅក្នុង "ឧបសម្ព័ន្ធ(ក) និង(ខ) នៃកិច្ចសន្យានេះ" ។

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងធ្វើកិច្ចសន្យាខ្ចីបរិភោគដែលមានចែងនៅក្នុងចំណុចខាងលើ ។

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងធ្វើសិទ្ធិលើការបញ្ចាំ ពន្យា លើសិទ្ធិនៃចំណុចទាដើម្បីធានាសិទ្ធិលើបំណុលដែលមានចែងនៅចំណុចទី២ ខាងលើ និងប្រគល់កម្មវត្ថុអោយទៅភាគី -ខ- ។

**៣. អត្តសញ្ញាណអចលនវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ**

(១). ទីតាំងដីស្ថិតនៅ: ផ្ទះលេខ:.......... ផ្លូវលេខ:.......... ភូមិ.......... សង្កាត់..........
ខណ្ឌ.......... រាជធានីភ្នំពេញ ។

(២). លេខក្បាលដី..........

(៣). លេខប័ណ្ណ:..........

**៤. ខសន្យាផ្សេងៗទៀត**

ភាគី -ក- និងភាគី -ខ- បានព្រមព្រៀងធ្វើកំណត់អំពីលក្ខខណ្ឌផ្សេងៗទៀតដូចមានចែងនៅក្នុងឧបសម្ព័ន្ធ (ក) នៃកិច្ចសន្យានេះ ។

ធ្វើជា..........ច្បាប់ នៅថ្ងៃទី.......... ខែ.......... ឆ្នាំ២០១៦

**បានអានសេចក្តីនៃលិខិតនេះអោយគូភាគីស្តាប់ចំពោះមុខសាក្សី**

ឈ្មោះ.......... អាយុ.......... ឆ្នាំ ទីលំនៅសង្កាត់.......... ខណ្ឌ..........
រាជធានីភ្នំពេញ ។

ឈ្មោះ.......... អាយុ.......... ឆ្នាំ ទីលំនៅសង្កាត់.......... ខណ្ឌ..........
រាជធានីភ្នំពេញ ។

| **ស្នាមមេដៃ** | **ស្នាមមេដៃ** | **បានឃើញ និងបញ្ជាក់ថា** |
|---|---|---|
| ភាគី -ក- | ភាគី -ខ- | គូភាគីបានផ្តិតមេដៃចំពោះមុខមេធាវីជាសាក្សី |